ភីណាតបដោយគ្រវីក្បាល៖

-អត់ទេ! មីងទៅចុះ!

ស្រស់ស្រីដើរសំដៅទៅបន្ទប់ទទួលភ្ញៀវ នាងអង្គុយនៅលើសាឡុងផ្អែកក្បាលទៅនឹងបង្អែកដោយអារម្មណ៍មិនសូវល្អ នាងរវើក្អែកសម្លឹងផ្ទៃបន្ទប់ដែលធំល្វឹងស្ងាត់ស្ងៀម មិនបានស្ដាប់ឮសម្ដីក្មេងតូចនោះគឺមិនអីទេ ប៉ុន្តែពេលនេះ មានអារម្មណ៍សង្ស័យ និងភ័យខ្លាចលាយឡំគ្នាក្នុងចិត្តមាណវី ផ្ទះធំយ៉ាងនេះមនុស្សក៏តិចគ្នាទៀត បើមិនខ្លាចក៏មិនសមដែរ។

អ្នកអួនដើរចេញពីបន្ទប់បាយដោយមានកាន់ចានផ្លែឈើមកជាមួយផង គាត់ដាក់ផ្លែឈើលើតុពីមុនភីណាទាំងបន្លឺ៖

-នាងតូចពិសាផ្លែឈើសិនទៅ ពិសាច្រើនបន្តិចក៏ល្អដែរនឹងអាលបានឆាប់ជាសះស្បើយ!

ភីណាឆ្លៀតឱកាសនោះពោលសួរតិចៗទៅកាន់អ្នកបម្រើចំណាស់ភ្លាម៖

-មីងអួ៎! ស្រីនោះមិនទាន់ចុះមកទេមែនទេ?

កាលបើឮនាងក្រមុំពោលសួរដូច្នេះ គាត់ពោលខ្សឹបៗតបភ្លាម៖

-នាងតូច មិនដឹងទេ! ប៉ុន្មានថ្ងៃមកនេះ អ្នកស្រីចម្លែកអញ្ចឹង មិនសូវចុះមកខាងក្រោមទេ! គាត់សម្ងំតែនៅខាងលើបន្ទប់ សូម្បីតែទឹកដោះគោឆៅដែលគាត់ធ្លាប់ចូលចិត្តពិសាពេលព្រឹកនោះ ខ្ញុំយកឡើងទៅជូនដល់បន្ទប់ ក៏គាត់ឆ្លើយមកថាមិនត្រូវការដែរ ខ្ញុំខ្លាចក្រែងអ្នកស្រីមានជំងឺអ្វីទេដឹង?

## ភាគទី៦

ភីណាដៀងភ្នែករិះគិត នាងយល់ថាបងថ្លៃខ្លួនដាច់ខ្យល់ស្លាប់ហើយបែរជារស់ឡើងវិញ គឺជារឿងខុសពីប្រក្រតីទៅហើយ ពេលនេះសភាពរស់នៅរបស់គាត់បានប្ដូរផ្លាស់ទៅជាចម្លែកយ៉ាងនេះទៀត កាន់តែបង្កើតនូវក្ដីងឿងឆ្ងល់ខ្លាំងឡើងៗក្នុងចិត្តនាង នាងរឹតតែយល់ទៅទៀតថាបងថ្លៃខ្លួនម្នាក់នេះចំជាលាក់នូវអាថ៌កំបាំងណាមួយដែលខ្លួន គិតមិនយល់ទាល់តែសោះ។ ភ្លាមនោះនាងស្រមៃដល់ស្នាមញញឹមត្រជាក់ស្រឹបដែលគាត់ញញឹមមកកាន់នាងឯមាត់បន្ទប់គេងកាលពីយប់ម្សិល ស្នាមញញឹមដែលគ្មានលក្ខណៈដូចទៅនឹងស្នាមញញឹមរបស់មនុស្ស

ធម្មតាសោះ គាត់មានរូបរាងជាបងថ្លៃរបស់ខ្លួនមែន ប៉ុន្តែកាយវិការបានផ្លាស់ប្ដូរស្ទើរតែទាំងអស់ទៅហើយ នាងបានផ្លាស់ប្ដូរស្ទើរតែទាំងអស់ទៅហើយ នាងនៅតែយល់ថាបងថ្លៃពិតប្រាកដរបស់ខ្លួន បានបាត់បង់ទៅតាំងតែពីយប់ដែលមានភ្លៀងធំនោះម្ល៉េះ។

ខណៈនោះនាងងាកទៅរកអ្នកបម្រើចំណាស់ ដោយពោលសួរពីរឿងផ្សេង៖

-មីងអួន! មីងមានសំគាល់ឃើញទេថាអ្នកម៉ុំនេះគេពុំសូវមកក្បែរផ្ទះយើងប៉ុន្មានទេ មែនទេ?

អ្នកបម្រើចំណាស់សញ្ជឹងគិតបណ្ដើរងក់ក្បាលផ្ងក់ៗ ឆ្លើយតបបណ្ដើរ៖

-មែន! នៅផ្លូវខាងដើមមនុស្សអ៊ូអរណាស់ ប៉ុន្តែដូចជាគ្មានអ្នកណាមកក្បែរម៉ុំផ្ទះយើងសោះ ព្រឹកអញ្ចឹងនៅមានគេទៅមកខ្លះ ចាប់ពីរសៀលទៅស្ងាត់ច្រៀប!

ភីណាសួរវិញភ្លាមដែរ៖

-មីងឧស្សាហ៍ចេញទៅក្រៅ មានធ្លាប់ឮគេនិយាយអំពីផ្ទះយើងដែរទេ?

អ្នកអួនគ្រវីក្បាល គាត់បន្លឺតប៖

-ទេ! ខ្ញុំចេញក៏ចេញផុត ចូលក៏ចូលផុត មិនដែលឮអ្នកណានិយាយអីទេ ប៉ុន្តែ អុះ! ខ្ញុំនឹកឃើញហើយនាងតូច។

ភីណាបើកភ្នែកមូលក្លុំសម្លឹងអ្នកបម្រើចំណាស់ទាំងមាត់ពោលសួរយ៉ាងរហ័ស៖

-រឿងអីទៅមីង?

អ្នកបម្រើរូបនោះប្រញាប់ប្រញាល់ឆ្លើយភ្លាម៖

-កាលទើបនឹងរើមកនៅបានពីរបីថ្ងៃ ខ្ញុំ និងអ្នកម៉ាប់ចេញទៅចាក់សំរាម គាត់ជួនបានជួបបងស្រីម្នាក់គាត់នៅក្បែរជិតខាងយើងនេះដែរ គាត់សួរមកខ្ញុំថាមកនៅប៉ុន្មានថ្ងៃហើយ មានដែលឃើញអ្វីទេ? ខ្ញុំ និងអ្នកម៉ាប់ឆ្ងល់ដែរ គេសួរអញ្ចឹង កាលណោះអ្នកម៉ាប់មានសួរទៅបងស្រីនោះវិញដែរថា "ឃើញអ្វីទៅ?" ប៉ុន្តែស្រាប់តែបងស្រីនោះលែងតបម្ទីម្នាដើរចេញទៅបាត់។ ក្រោយមិនដែលឮអ្នកណានិយាយអីទេ! អ្នកជិតខាងម៉ុំនេះចំជាចម្លែកណាស់នាងតូច ថ្ងៃមួយនោះខ្ញុំ និងអ្នកម៉ាប់ឡើងទៅហាលខោអាវនៅខាងលើ ជ្រុលដៃធ្វើជ្រុះឈើដែលដាក់ធ្វើជាស្ន

ឮសូរបន្តិចបន្តួចប៉ុណ្ណោះ ក៏ស្រាប់តែក្រឡេកទៅឃើញផ្ទះប៉ុន្មានក្បែរយើងនេះ គេបិទបង្អួចគ្រាំងៗ ខ្ញុំគិតថាអ្នកនៅផ្ទះជាប់យើងទាំងប៉ុន្មាននេះដូចជាចម្លែកយ៉ាងម៉េចទេ។

ភីណាពោលសួរទៅកាន់អ្នកបម្រើវិញ៖

-យើងធ្លាប់ធ្វើអ្វីប៉ះពាល់ទៅលើគេដែរ?

-អត់មានទេ! អត់មានសោះនាងតូច!

ភីណានៅស្ងៀមដោយសញ្ជឹងគិត ខណៈនោះអ្នកបម្រើរូបនោះពោលរបៀបភ្ញាក់៖

-យី! ភ្លេចទឹកដាំចោលផង ខ្ញុំចូលទៅមើលទឹកសិន!

អ្នកបម្រើរូបនោះចូលទៅចង្ក្រានបាត់ ភីណាក្រោកដើរចេញមកសួនផ្កាខាងក្រៅផ្ទះ នាងសញ្ជឹងគិតពីរឿងដែលអ្នកបម្រើបានរៀបរាប់អម្បាញ់មិញ នាងក្រមុំងើបមុខសម្លឹងគេហដ្ឋានអ្នកជិតខាងដែលនៅអមសងខាង បង្អួចទាំងនោះពិតជាបានបិទជិតទាំងអស់មែន ភីណានៅតែមិនយល់ថា ហេតុអ្វីបានជាផ្ទះខ្លួនក្លាយកន្លែងអ្នកផងមិនជិតស្និទ្ធយ៉ាងនេះ ឬមួយថាមានអ្វីម្យ៉ាងដូចក្មេងស្រីជំទង់នៅឯហាងបានប្រាប់មែន?

កំពុងដើរបណ្ដើរ លង់អារម្មណ៍ក្នុងការត្រិះរិះបណ្ដើរក៏ស្រាប់តែរបស់មួយប្លាតពីរបងម្ខាងចូលមកក្នុងបរិវេណផ្ទះរបស់នាង ដែលភីណាមើលស្គាល់ថានោះគឺជាបាល់មួយ។ នារីយល់ថាទំនងជាអ្នកជិតខាងក្បែរនេះបានលេងបណ្ដាលឲ្យប្លាតមកដោយអចេតនាហើយទើបនាងរេសម្លឹងទៅបាល់ដែលរមៀលលើដីមកក្បែរជើង ហើយឈ្ងោកបម្រុងនឹងរើស ប៉ុន្តែភ្លាមនោះចុងកន្ទុយភ្នែកដូចជាមានអារម្មណ៍ថាមានគេម្នាក់កំពុងឡើងពីរបងម្ខាងអើតមុខសម្លឹងមក។ ភីណាងាកសម្លឹងទៅទីនោះយ៉ាងរហ័ស នាងឃើញក្មេងប្រុសម្នាក់ក្នុងវ័យប្រមាណ ៥ ឬ៦ឆ្នាំបើកភ្នែកភ្លឹះៗ សម្លឹងមកនាង បន្ទាប់មកភ្នែកដៀងសម្លឹងមកបាល់ដែលនៅលើដីនៅឡើយ។ ភីណាយល់ថាក្មេងប្រុសមានបំណងចង់រើសបាល់របស់គេ ក៏ពោលទៅកាន់ស្វាគមន៍ដោយញញឹម៖

-បាល់របស់អូនឯង?

ក្មេងប្រុសឆ្លើយតបភ្លាមដែរ៖

-បាទ!

ភីណាឱនរើសបាល់មកកាន់ដោយញញឹមដដែលងាកសម្លឹងទៅក្មេងតូច នាងពោលសួរបន្ថែម៖

-ចុះអូនឯងលេងបាល់ជាមួយអ្នកណា?

ក្មេងតូចក្របួចមាត់តបដោយទឹកមុខស្លូត៖

-លេងម្នាក់ឯង!

ភីណាបើកភ្នែកមូលក្រឡង់សម្លឹងទៅក្មេងតូចដោយកាន់បាល់នៅនឹងដៃ ដើរចូលទៅជិតវាផង៖

-លេងតែម្នាក់ឯងទេ? ម៉េចហ្នឹងសប្បាយទៅ? អ៊ីចេះចុះ ចាំបងលេងជាមួយអូខេ?! យើងលេងជាមួយគ្នាទៅ ព្រមអត់?

ក្មេងតូចធ្វើភ្នែកម៉ក់ៗ សម្លឹងមកភីណារបៀបគិតមុនជឿជាក់។ យល់ចិត្ត ទើបនាងញញឹមពោលប្រាប់សាជាថ្មី៖

-អូនមកខាងណេះមក! មកខាងណេះលេងជាមួយបងណ៎ា!

ក្មេងតូចហើបមាត់តបវិញភ្លាម៖

-បងស្រីចេះលេងបាល់មែន?

ភីណាញញឹម នាងបន្លឺតបភ្លាមដែរ៖

-ចេះ! រឿងអីថាមិនចេះ! តែអូនឆ្លងមកខាងណេះមក!

ក្មេងតូចញញឹមស្រស់ ភីណាឃើញក្មេងនោះចុះពីរបងបាត់ទៅ។ នាងដឹងថាគឺកំពុងតែដើរមកផ្ទះខ្លួន ដូច្នេះទើបនាងដើរទៅឈរចាំឯមាត់ទ្វារជាស្រេច។ មួយខណៈគឺក្មេងប្រុសរត់សំដៅមកមែន។

នាងនាំក្មេងប្រុសចូលក្នុងបរិវេណផ្ទះ ទាំងពោលប្រាប់វា៖

-យើងទៅលេងទីធ្លាខាងក្រោយណា អូនញ៉ាំទឹកក្រូចទេ ចាំបងហៅគេយកឲ្យញ៉ាំ អូខេ?

ក្មេងតូចញញឹមស្រស់ហើយងក់ក្បាលញាប់ស្មេក ប៉ុន្តែមិនទាន់បានឆ្លើយតបថាយ៉ាងណាផង ក៏ស្រាប់តែភ្លាមនោះឮសូរសំឡេងរន្ធត់លាន់មកឯមាត់ទ្វាររបង៖

-ស្លាប់ហើយកូន! មកវិញ មកវិញភ្លាម! ម៉េចក៏មកលេងទីនេះ?

ភីណាសម្លឹងទៅស្ត្រីម្ចាស់សំឡេងដោយក្តីងឿងឆ្ងល់។ នាងយល់ថាគាត់មានអាការទំនងជាភ្ញាក់ផ្អើលខ្លាំងកាលបើគាត់ឃើញកូនគាត់ចូលមកដល់ផ្ទះនាង។ ខណៈនារីអភិជនស្រឡាំងកាំង ស្ត្រីជាម្តាយក្មេងដែលមិនត្រឹមតែមិនខ្វល់ញញឹមស្វាគមន៍នាង គឺថែមទាំងស្តីបន្ទោសទៅកាន់ក្មេងតូចចាស់ដៃ៖

-ម៉ែប្រាប់ថាម៉េច? អ្ហះ? ថាកុំឲ្យមកលេងក្បែរនេះ ម៉េចមិនស្តាប់ម៉ែ?

ភីណាសម្លឹងទៅកុមារតូចដែលកំពុងជ្រប់មុខរបៀបទទួលកំហុស។ នាងយល់ថាមិនសមហេតុផលសោះដែលអ្នកស្រីម្តាយធ្វើទៅលើកូនគាត់របៀបនេះ នាងចង់និយាយហេតុផលពន្យល់គាត់ ប៉ុន្តែមិនទាន់បានហើបមាត់ផង គាត់អូសដៃកុមារតូចដើរលឿនស្លេវចេញទៅរកតែនាងក្រមុំហាមិនទាន់សូម្បីមួយសំឡេង។

ភីណាបែរខ្នងដើរចូលមកខាងក្នុងវិញយឺតៗ ខណៈដែលនាងនៅតែឮសំឡេង ស្ត្រីដដែលបន្តរអ៊ូបន្ទោសកូនប្រុស៖

-កូនឯងម៉េចមិនស្តាប់ម៉ែ? ម៉េចក៏ទៅលេងផ្ទះហ្នឹង? ចាំមើលបើថ្ងៃក្រោយកូនទៅផ្ទះហ្នឹងទៀត ម៉ែនាំកូនទៅនៅផ្ទះយាយឯងរហូតហើយ!

ភីណានៅសម្ងំស្ទៀមស្តាប់ពាក្យសម្តីរបស់ស្ត្រីម្តាយក្មេងប្រុសដែលកំពុងបន្ទោសកូនឯរបងម្ខាង ខណៈនោះនាងឮក្មេងនោះពោលតបទៅកាន់ម្តាយ៖

-ម៉ែ! ម៉ែថាផ្ទះនោះមានខ្មោច តែកូនទៅអម្បាញ់មិញអត់ឃើញខ្មោចផង!

សំឡេងពីរនាក់ម្តាយ និងកូនកាន់តែឆ្ងាយៗទៅ តាមមើលគឺពួកគេចូលផុតទៅក្នុងផ្ទះទៅហើយ ប៉ុន្តែពាក្យថា "ផ្ទះនោះមានខ្មោច" របស់ក្មេងប្រុសអម្បាញ់មិញដែលនិយាយទៅកាន់ម្តាយ នៅតែលាន់រងំនៅក្នុងត្រចៀកនាងក្រមុំនៅឡើយ ភីណាកាន់តែយល់ច្បាស់ជាងមុនថាម៉េចបានជាអ្នកជិតខាងទាំងនោះនៅក្នុងសភាពដាច់ឆ្ងាយពីគ្រួសារខ្លួនម្ល៉េះ សូម្បីតែទំនាក់ទំនងបន្តិចបន្តួចក៏មិនដែលមានដែរ។

នាងក្រមុំកាន់បាល់ដើរមួយៗចូលក្នុងផ្ទះដោយអារម្មណ៍តានតឹង។ ពេញមួយថ្ងៃនាងអង្គុយត្រិះរិះមិនអស់មិនហើយពីលំនៅឋានរបស់ខ្លួន ម៉េចក៏ពួកគេនាំគ្នានិយាយពីផ្ទះខ្លួនបែបនេះ? មានខ្មោច? គួរតែជឿ ឬក៏គួរបន្ទោស?

ល្ងាចនេះបងប្រុសនាងមិនបានត្រឡប់មកផ្ទះអាស្រ័យបាយទេ ព្រោះថាគាត់ជាប់ទៅទទួលទានជាមួយភ្ញៀវ ដើម្បីទំនាក់ទំនងការងារជំនួញ ក្នុងផ្ទះសល់តែភីណា និងស្រីជាបងថ្លៃប៉ុណ្ណោះ ប៉ុន្តែពេញមួយថ្ងៃមកនេះអ្នកស្រីវ័យក្មេងមិនបានចុះមកជាន់ខាងក្រោមសោះ សូម្បីតែពេលបាយទាំងពីរលើកក៏ដោយ។

ទោះបរិយាកាសផ្ទះមានភាពចម្លែកយ៉ាងនេះក្តី ប៉ុន្តែភីណានៅតែមិនរវល់ ត្បិតអីនាងក៏មិនចង់ជួបមុខបងថ្លៃដែលនាងយល់ថា "គួរឲ្យសង្ស័យ" នេះឡើយ។

នាងទទួលទានបាយតែម្នាក់ឯងគត់ រហូតដល់មេឃងងឹតបន្តិចស្រស់ស្រីឡើងទៅសម្ងំអានសៀវភៅក្នុងបន្ទប់ឯជាន់ខាងលើ។

បរិយាកាសស្ងាត់ស្ងៀមចេះតែកន្លងទៅមុខ រហូតដល់យប់ងងឹតមែនទែន ទើបភីណាដកភ្នែកពីសៀវភៅក្រោកពត់ខ្លួនពត់ប្រាណបម្រុងបើកទូរទស្សន៍មើលតែអផ្សុក ប៉ុន្តែភ្លាមនោះស្រាប់តែត្រចៀកដូចជាបានឮសម្រិបជើងមនុស្សរត់រសឹបឯក្រៅបន្ទប់។

ភីណាផ្ទៀងត្រចៀកស្តាប់ដោយក្តីងឿងឆ្ងល់ នាងដឹងថាខ្លួនមិនច្រឡំទេ ខាងក្រៅពិតជាមានមនុស្សកំពុងរត់មែន ណាមួយសម្រិបជើងដូចជាមានច្រើនគ្នាទៀតផង ភីណាត្រិះរិះដោយប្រយ័ត្នប្រយែង បងប្រុសខ្លួនមិនទេ ស្នូរជើងរត់រសឹបខាងក្រៅបន្ទប់តើជាអ្នកណាទៅ? អ្នកបម្រើក៏មិនសមថាហ៊ានឡើងមកជាន់ខាងរត់ឆ្លេឆ្លាក្នុងវេលាយប់ស្ងាត់អញ្ចឹងដែរ ប៉ុន្តែបើមិនមែនជាសម្រិបជើងរបស់សមាជិកក្នុងផ្ទះ តើជារបស់អ្នកណាទៅវិញ?

អារម្មណ៍ភ្ញាក់ផ្អើលមួយលេចភ្លែតដោយស្វ័យប្រវត្តិក្នុងចិត្តមាណវី នាងនឹកដល់សម្តីក្មេងស្រីជំទង់ដែលនិយាយដោយទឹកមុខបារម្ភប្រាប់នាងថា "ផ្ទះនោះមានខ្មោច" ភីណាដឹងថាចុងដៃខ្លួនកំពុងចាប់ផ្តើមត្រជាក់ដូចទឹកកក ឯបេះដូងក៏កំពុងលោតញាប់រន្ទាន់ដែរ រួមជាមួយគ្នានោះសម្រិបជើងខាងក្រៅនៅតែឮរសឹបចុះឡើងមិនព្រមបាត់សោះ ភីណាផ្ទៀងត្រចៀកស្តាប់ផង បែកញើសជោគរាងកាយដោយក្តីសង្ស័យផង នាងក្រមុំសម្ងំស្ងៀមដោយតាំងចិត្តថា មកពីអារម្មណ៍ខ្លួនមិននឹងនទេ នាងប្រឹងតាំងចិត្តមួយដងជាពីរដង ប្រាប់ខ្លួនឯងថាលើលោកនេះ

គ្មានខ្មោចពីណាមកទេ។ សំរិបជើងរត់ខាងក្រៅដែលខ្លួនឮអម្បាញ់មិញ គឺជាសូរមែកឈើទង្គិចគ្នាក្រោមកម្លាំងខ្យល់តែប៉ុណ្ណោះ ប៉ុន្តែសូរសំរិបជើងនៅតែរត់ចុះឡើងទៅមកមិនឈប់ឡើយ ខាងក្រៅបន្ទប់ប្រាកដជាមានគេកំពុងរត់ចុះឡើងៗមែន កាន់តែឮក៏កាន់តែនៅមិនសុខ នាងមិនមែនស្ទុះមកទទូរភួយសម្ងំសុខនោះទេ ប៉ុន្តែបែរជាលូកដៃមួលសោទ្វារបន្ទប់បើកឃើតៗ ឈានមួយជំហានហើយមួយជំហានទៀត មកខាងក្រៅបន្ទប់។

កណ្តាលបរិយាកាសស្ងាត់ជ្រងំនៃភូមិឋានធំល្វឹង ស្រស់ស្រីភ្នែកសម្លឹងជុំវិញទីនោះដោយបេះដូងលោតក្តុកក្តាក់ដូចគេទូងស្គរ នាងសម្លឹងដល់មាត់ទ្វារបន្ទប់បងប្រុសខ្លួន បន្ទាប់មកបន្ទប់វត្ថុបុរាណ បន្ទប់ធ្វើការរបស់បងប្រុស បន្ទប់ដាក់សៀវភៅ ទ្វារទាំងនោះសុទ្ធតែបិទជិតឈឹងទាំងអស់ រកមើលស្រមោលមនុស្សម្នាក់ក៏មិនឃើញដែរ ភីណាថយក្រោយក្រាកៗមកប៉ះនឹងទ្វារបន្ទប់វិញ អារម្មណ៍ទាំងមូលដូចជាច្រាស់ច្រាល់ក្នុងសភាពភ័យខ្លាចច្រើនជាងមុន ទោះបីថាសូរសម្រិបជើងលែងមានឮទៀតក៏ដោយ។

ស្រស់ស្រីយកដៃជូតតំណក់ញើសដែលស្រក់មកលើថ្ងាសមិនឈប់ឈរ អម្បាញ់មិញពិតជាបានឮសម្រិបជើងមនុស្សច្បាស់លាស់ណាស់ ពេលនេះម៉េចក៏បែរជាស្ងាត់ជ្រងំយ៉ាងនេះ? មានគេកំពុងលលេងជាមួយខ្លួនទេដឹង?

វាំងនននឯបង្អួចធំខាងកើតកំពុងបំប៉ើងខ្លួនយ៉ាងខ្ពស់តាមកម្លាំងខ្យល់ដែលបក់មកយ៉ាងសន្ធាប់ពីខាងក្រៅ ភីណាទទួលអារម្មណ៍ថាក្រៅពីការភ័យខ្លាច នៅមានក្តីមួហ្មងបង្កប់ក្នុងចិត្តទៀតផងដែរ នាងកំពុងបន្ទោសស្ងាត់ៗក្នុងចិត្តថា ម៉េចក៏អ្នកបម្រើអស់នេះធ្វេសប្រហែសចំហបង្អួចចោលយ៉ាងនេះ? នាងក្រមុំដើរសំដៅទៅកាន់មាត់បង្អួច លូកដៃទាញផ្ទាំងបង្អួចកញ្ចក់បិទមកវិញ។

ដងខ្លួនទាំងមូលប៉ះជាមួយនឹងខ្យល់ត្រជាក់គួរឲ្យស្រៀវស្រាញណាស់ ហៀបនឹងដើរសំដៅមកកាន់បន្ទប់វិញទៅហើយ ក៏ស្រាប់តែភ្លាមនោះចុងកន្ទុយភ្នែកបានវាត់ទៅប៉ះនឹងស្រមោលអ្វីម្យ៉ាងឯជណ្តើរ ដែលឡើងបន្តទៅរានហាលខាងលើ ភីណានៅទ្រឹងមួយកន្លែងទាំងទ្រូងលោតដុកដាក់ៗ នាងនៅមិនទាន់ហ៊ានដៀងភ្នែកសម្លឹងទៅនៅឡើយ ប៉ុន្តែនាងបានកំណត់ដោយជឿជាក់ក្នុងចិត្តរួចជាស្រេចហើយថា នៅទីនោះស្រមោលដែលខ្លួនបានប្រទះនោះ គឺប្រាកដជាវត្ថុមានជីវិតពិតណាស់ បាតដៃទាំងគូដែលទទឹកជោកទៅដោយតំណក់ញើស បាន

ក្ដាប់យ៉ាងណែន ប៉ុន្ដែនាងនៅមិនទាន់មានសេចក្ដីក្លាហានគ្រប់គ្រាន់នឹងងាកសម្លឹងឲ្យចំទៅទីនោះសោះ។

ក្នុងស្ថានភាពរបៀបនេះ ត្រូវធ្វើយ៉ាងម៉េចក៏នាងមិនដឹងដែរ ចង់ស្រែកក៏មិនទាន់ប្រាកដថាស្រែកចេញសំឡេងឡើយ ព្រោះថាសភាពរន្ធត់ញាប់ញ័រកំពុងរុករានទន្ទ្រានរាងកាយនាងរាងកាយយ៉ាងខ្លាំងក្លាបំផុតទៅហើយ។ ប៉ុន្ដែ មនុស្សយើងគឺចម្លែកត្រង់ម្យ៉ាង អ្វីដែលពិបាកទទួលយកបំផុតក៏បែរជាចូលចិត្តសម្លឹងមើលបំផុតដែរ ភីណាស្ថិតក្នុងសភាពតឹងតែងបំផុតក៏បែរជាមានសន្ទុះចិត្តចម្លែក អ្វីម្យ៉ាងមកជំរុញឲ្យនាងបែរខ្លួនងាកសម្លឹងទៅកាន់មាត់ជណ្ដើរឡើងទៅរានវាលនោះភ្លាមដែរ ប៉ុន្ដែលើកនេះស្រមោលដែលខ្លួនប្រទះឃើញអម្បាញ់មិញបែរជាបាត់សូន្យដូចកាលដែលត្រចៀកបានឮសម្រិបជើងអញ្ចឹងដែរ។

ម្ដងនេះលែងគិតច្រើនទៀតហើយ នាងក្រមុំលើកសំពត់រាត្រីឲ្យខ្ពស់ផុតកជើងរត់រឹងយ៉ាងរហ័សចុះតម្រង់ទៅកាន់ជាន់ខាងក្រោមភ្លាម នាងរត់បណ្ដើរមាត់ស្រែកបណ្ដើរ៖

-មីងអួន! មីងម៉ាប់! មីងអួន!?

សូរសម្រែករបស់តរុណីវ័យក្មេងលាន់រំពងគេហដ្ឋានដែលធំទូលាយហើយស្ងាត់ជ្រងំ អ្នកបម្រើចំណាស់ទាំងពីររត់ចេញពីកន្លែងសម្រាកសំដៅមកកាន់ផ្ទះធំ កាលបើឮសម្រែកឆោឡោដោយក្ដីតក់ស្លុតរបស់តរុណីវ័យក្មេង។ ជាមួយគ្នានោះដែរសូហ្វ័រចំណាស់ដែលកំពុងសម្រាកខាងក្រោយផ្ទះក៏ស្ទុះចូលមកដែរ។ គាត់ទាំងបីឈរសម្លឹងនាងក្រមុំភីណាដែលកំពុងប្រកបដោយទឹកមុខភិតភ័យរត់ចុះយ៉ាងរហ័សមកពីជាន់ខាងលើ មីងអួនដែលជាអ្នកថែទាំជិតស្និទ្ធនឹងនាងក្រមុំជាងគេ គាត់ស្ទុះមករកនាងដោយពោលសួរយ៉ាងរហ័ស៖

-នាងតូច មានរឿងអី? មានរឿងអី? មានរឿងអីហ្នឹងនាងតូច?

ភីណាដែលប្រកបដោយទឹកមុខស្វាយល្អក់ពោលតបដោយសំឡេងញ័ររន្ធត់៖

-ខ្មោច ខ្មោចលង ខ្មោចលង មីង!

មីងអួនបង្ហាញទឹកមុខងឿងឆ្ងល់ ប៉ុន្ដែគាត់នៅមិនទាន់ពោលសួរយ៉ាងណានៅឡើយ ស្រាប់តែមីងម៉ាប់ដែលនៅឈរកណ្ដាលបន្ទប់ពោលសួរវិញ៖

-នាងតូច យល់សប្ដិអាក្រក់មែនទេ?

**ភាគទី៧**

ភីណាឆ្លើយតបយ៉ាងរហ័ស ហាក់ដូចជាខ្លាចថាពួកគេមិនជឿសម្ដីខ្លួន៖

-ទេ! ខ្មោច មានខ្មោចមែន នៅខាងលើ នៅខាងលើណាមីង!

អ្នកបម្រើចំណាស់ទាំងបីងើបមុខសម្លឹងខាងលើព្រមៗគ្នា ប៉ុន្តែទឹកមុខរបស់ពួកគេមិនដូចជាជឿតាមសម្ដីនាងក្រមុំទាល់តែសោះ ដឹងថាសម្ដីខ្លួនមិនបានធ្វើឲ្យពួកគេជឿជាក់នៅឡើយ ភីណាពោលបន្ថែមភ្លាម៖

-យ៉ាងម៉េច? អត់អ្នកណាជឿខ្ញុំទេ?

ភីណាងាករកអ្នកបម្រើដែលជិតស្និទ្ធជាងគេ នាងបន្លឺតបទៅកាន់គាត់៖

-នៅខាងលើ វារត់ចេញពីបន្ទប់ហើយ ហើយខ្ញុំបានឃើញស្រមោល ស្រមោលឡើងទៅខាងលើទៀតផង!

អ្នកបម្រើចំណាស់បង្ហាញក្ដីងឿងឆ្ងល់លើផ្ទៃមុខលើសដើម គ្មានសញ្ញាណាបញ្ជាក់ថាគាត់មានក្ដីភិតភ័យបន្តិចណាសោះ គាត់តបមួយៗ៖

-តោះ! មីងជូនឡើង អត់មានខ្មោចពីណាមកទេ!

ភីណានៅរុញរានៅឡើយ នាងពោលតបទៅកាន់គាត់៖

-ខ្ញុំឃើញមែនមីង! ខ្ញុំឃើញមែន! ជឿខ្ញុំទៅផ្ទះនេះមិនស្រួលទេ!

អ្នកអួនងក់ក្បាលផ្ញក់ៗ គាត់ដឹងថានាងក្រមុំកំពុងត្រូវក្ដីភ័យរន្ធត់សង្កត់ចិត្តមិនទាន់បានស្រាយរួចនៅឡើយ អញ្ចឹងហើយទើបគាត់ប្រឹងពោលលួងលោម៖

-អត់ទេ នាងតូចច្រឡំក៏មិនដឹង ទុកមីងជូនឡើងទៅមើលចុះ! តោះ មីងជូនឡើង។

ភីណានៅរារែក មិនទាន់ឈានជើងមួយជំហានណានៅឡើយ អ្នកសូហ្វ៊ីរឡានលូកមាត់ពោលដោយឈានតម្រង់មកជណ្ដើរ៖

-អត់មានទេនាងតូច! យើងនាំគ្នាឡើងទៅមើលទៅ បើនាងតូចបានឮសំឡេងជើងមែន ក្រែងមានមនុស្សលួចចូលផ្ទះ!

មីងម៉ាប់ឮដូច្នេះក៏ដូចជានឹកបារម្ភដែរ គាត់ពោលបន្ទរបន្ថែម៖

-ត្រូវហើយ យើងឆាប់ឡើងទៅមើលភ្លាម មានចោរក៏មិនដឹង!

អ្នកបម្រើទាំងបីស្ទុះស្ទាឡើងជណ្តើរតម្រង់ទៅជាន់ខាងលើ នាងក្រមុំភីណា ងើបមុខសម្លឹងដំណើរពួកគាត់ នាងឈានជើងឡើងតាមក្រោយឃើតៗ ដោយក្តីភិតភ័យមិនទាន់រលាយបាត់ពីទ្រូងនៅឡើយ។

អ្នកបម្រើទាំងបីដើរនាំមុខដោយប្រយ័ត្នប្រយែង ឡើងមកដល់ជាន់ទីមួយរួចបង្អួសឡើងទៅរានហាលខាងលើទៀត ប៉ុន្តែភីណាទទួលអារម្មណ៍ថាចម្លែកណាស់ បរិយាកាសលើកនេះបែរជាស្ថិតក្នុងសភាពស្ងៀមស្ងាត់ធម្មតា កុំថាឡើយខ្មោច សូម្បីតែកូនកណ្តុរមួយក៏មិនមានប្រទះផង!

នាងក្រមុំរអ៊ូដោយមិនសប្បាយចិត្ត៖

-ឃើញឡើងត្រង់នេះច្បាស់ណាស់ ម៉េចក៏ឥឡូវមិនឃើញអញ្ចឹង?

អ្នកបម្រើទាំងបីរូប សុទ្ធតែបានគិតសង្ស័យរៀងៗខ្លួនក្នុងចិត្តជាស្រេចរួចទៅហើយថានាងក្រមុំកាលពីត្រឡប់មកផ្ទះវិញកាលណា ហាក់ដូចជានាងត្រូវគ្រោះថ្នាក់ធ្វើឲ្យស្មារតីមិននឹងនយ៉ាងម៉េចទេ យប់នេះទៀត ក៏នៅសុខៗស្រែកឆោឡោភ្ញាក់គេឯង ប៉ុន្តែទោះបីជាក្នុងចិត្តម្នាក់ៗគិតយ៉ាងនេះក្តី ក៏មានអ្នកណានិយាយថាម៉េចដែរ មានតែពោលប្រាប់ថា៖

-អត់មានអីទេនាងតូច! យប់ណាស់ហើយចូលសម្រាកទៅ!

ពួកអ្នកបម្រើនាំគ្នាចុះទៅក្រោមអស់ ភីណាដើរត្រឡប់សំដៅមកកាន់បន្ទប់វិញដោយមិនអស់ចិត្ត នាងជឿថាខ្លួនមិនព្រិលភ្នែក ហើយក៏មិនរវើរវាយដែរ ខ្លួនបានឮសម្រិបជើង បានប្រទះស្រមោលម្យ៉ាងពិតណាស់។

-ចុះម៉េចក៏ពេលនេះ?

ស្រស់ស្រីដើរចូលបន្ទប់រុញទ្វារបិទទាំងមួហ្មង ទើបនឹងបែរខ្លួនមករកគ្រែក៏ស្រាប់តែភ្ញាក់ស្ទើរលោះព្រលឹង ត្បិតអីនៅក្នុងបន្ទប់នេះក្រៅពីនាងនៅមានវត្តមានមនុស្សប្លែកមុខពីរនាក់ទៀតកំពុងឈរបើកភ្នែកគ្រលួងកណ្តាលបន្ទប់សម្លឹងមកនាងដែរ។

**ភាគទី៦**

ភីណាស្ទើរមិនជឿភ្នែកខ្លួនឯង តរុណីសម្លឹងទៅមនុស្សមិនស្គាល់ពីរនាក់នោះ ក្នុងចំណោមនោះមានម្នាក់ជាស្រីវ័យក្មេងផង ឯម្នាក់ទៀតជាក្មេងប្រុសជំទង់ ពួកគេប្រកបដោយសម្លៀកបំពាក់រឹបខ្លួន។ ម្នាក់នៅលើដៃមានទាំងកាន់ម៉ាស៊ីនថត ម្នាក់ទៀតកាន់Tablet ។ ភីណាភ្លាត់មាត់ស្រែកសួរភ្លាមៈ

-អ្នក....អ្នកទាំងពី...ជាអ្នកណា? ពួកឯងនាំគ្នាចូលមកទីនេះម៉េចបាន? ចោរ?.... ចោរមែនទេ!

ស្រីជំទង់លាន់ម៉ាត់តបវិញភ្លាមដោយទឹកមុខស្លូតបូត និងខ្លាចចិត្តៈ

-មិនមែនទេ! ពួកខ្ញុំមិនមែនចោរទេ កុំស្រែកអី!

ស្រីរូបនោះពោលបណ្ដើរ ដើរចូលមកក្បែរភីណាបណ្ដើរ ធ្វើឲ្យនាងក្រមុំម្ចាស់បន្ទប់ថយក្រោយគ្រាកៗប៉ះនឹងទ្វារបន្ទប់ នាងពោលដោយមិនទាន់យល់៖

-មិនមែនចោរអ្ហេស៎!? បើមិនមែនលួចចូលមកផ្ទះគេទាំងយប់អធ្រាត្រយ៉ាងនេះធ្វើអី?

ស្រីក្មេងរូបនោះមិនទាន់បានតបវិញយ៉ាងណានៅឡើយ តែក្មេងប្រុសជំទង់ដែលកំពុងកាន់ម៉ាស៊ីនថតឈរពីក្រោយខ្នងនោះពោលតបមកកាន់ភីណាយ៉ាងរហ័សៈ

-ពួកខ្ញុំមកថតខ្មោច!

ការពិតទៅវត្តមានរបស់គេទាំងពីរបានធ្វើឲ្យភីណាភ្ញាក់ផ្អើលក៏ពិតមែន ប៉ុន្តែនាងក៏មានអារម្មណ៍ពីរនាក់នោះមិនសមទំនងថាចោរសោះដែរ លុះមកឮក្មេងប្រុសជំទង់នោះឆ្លើយតបយ៉ាងនោះទៀត នាងទៅជាហួសចិត្ត នាងពោលសួរវិញភ្លាម៖

-មកថតខ្មោច? និយាយច្រឡំ ឬមួយក៏ខួរក្បាលមានបញ្ហា? អ្នកណាប្រាប់ថាផ្ទះនេះតាំងរូបខ្មោចឲ្យចូលមកថត?

ក្មេងប្រុសនោះហៀបនឹងឆ្លើយតបទៅហើយ ក៏ស្រាប់តែគូកនរបស់គេឆ្លើយកាត់មុនៈ

-ពួកខ្ញុំបានជួបខ្មោចរួចហើយ...!មែនណ៎ា!

ភីណាសម្លឹងមុខគេទាំងពីរនាក់ គេទាំងពោលដោយមួហ្មង៖

-អូ្ហ! ខ្ញុំយល់ហើយ សម្រិបជើងរត់ចុះឡើងនៅខាងក្រៅអម្បាញ់មិញ គឺពីរនាក់ឯងមែនទេ? ចាំមើលចុះ ខ្ញុំប្ដឹងគេថាអ្នកទាំងពីរចូលមករំខានផ្ទះខ្ញុំ ប្រុងខ្លួនដេកប៉ុស្ដិ៍ប៉ូលិសទាំងពីរនាក់ទៅ!

ពោលចប់នាងងាកបម្រុងបើកទ្វារចេញពីបន្ទប់ ប៉ុន្តែស្រីក្មេងម្នាក់នោះបែរជារត់មករាំងពីមុខទ្វារជាប់ ណាមួយមានទាំងពោលអង្វរផង៖

-កុំធ្វើអញ្ចឹង! កុំធ្វើអញ្ចឹងអីណ៎ា!

ភីណាសម្លឹងស្រីក្មេងរូបនេះដោយពិនិត្យពិច័យ នាងពោលសួរដោយហួសចិត្ត៖

-អីគេ? ឯងជាស្រីទេ! មកស្លៀកពាក់ដូចប្រុសទៅកើត? ហើយមកលបចូលផ្ទះគេឯងទាំងយប់អធ្រាត្រ? តែរឿងបែបនេះក៏ហ៊ានធ្វើដែរ? បើគេចាប់ទៅប៉ុស្តិ៍ប៉ូលិសឯងគិតធ្វើម៉េច?

ស្រីរូបនោះហាក់ដូចជាមានបំណងយ៉ាងទទូចចង់ឲ្យគេជឿខ្លួន នាងពោលតបមកកាន់ក្រមុំម្ចាស់បន្ទប់៖

-ជឿខ្ញុំទៅ ខ្ញុំគ្មានបំណងអាក្រក់ទេ! មែនណ៎ា!

ភីណាសើចខឹកក្នុងបំពង់ក នាងពោលដោយហួសចិត្ត៖

-អត់បំណងអាក្រក់!? មានអ្នកមានបំណងល្អណាមួយដែលចូលផ្ទះអ្នកផងមិនឲ្យម្ចាស់គេដឹងនោះ! ហើយយកកាមេរ៉ាកុំព្យូទ័រមកពេញដៃទៀត រំលោភភាពឯកជនគេច្បាស់ណាស់? អញ្ចឹងចាំខ្ញុំលួចចូលរុករើផ្ទះឯងម្ដងលោមើល!

ស្ទើរតែភីណានិយាយមិនទាន់ចប់ផង ស្រីក្មេងរូបនោះងក់ក្បាលបន្លឹតបញ្ជាប់ស្មេរ៖

-បាន! បាន! យប់ស្អែក ឯងទៅផ្ទះខ្ញុំចុះ! ចាំខ្ញុំនិយាយរឿងហេតុនោះប្រាប់អូខេ?!

ភីណាកាន់ងឿងឆ្ងល់ នាងតបវិញទាំងមិនយល់អ្វីសោះ៖

-រឿង? រឿងអី? ហេតុអ្វី? ផ្ទះឯងនៅឯណា?

ស្រីក្មេងរូបនោះតបមកវិញដោយបើកភ្នែកមូលក្លុំ៖

-ផ្ទះខ្ញុំនៅជាប់ផ្ទះឯងខាងស្ដាំដៃនេះទេ! ឯងអត់ដឹងមែនអ្ហេស៎!?

ភីណាកាន់តែងឿងឆ្ងល់៖

-ម៉េចខ្ញុំមិនដែលឃើញឯង? ចង់មកបោកប្រាស់ខ្ញុំផង?

ក្មេងប្រុសជំទង់ដើរចូលមកជិត ពោលពន្យល់ប្រាប់ភីណា៖

-បងស្រីខ្ញុំទើបនឹងមកពីបរទេសទេ! គាត់ចេញទៅរៀនតាំងពីបងស្រីមិនទាន់រើមកនៅទីនេះម្ល៉េះ!

ភីណាសម្លឹងក្មេងប្រុសរួចរេភ្នែកសម្លឹងមកនារីដែលកំពុងឈរកក្បែរខ្លួន នាងក្រពាត់ដៃពោលសួរដោយហួសចិត្ត៖

-និស្សិតបរទេសផង? អញ្ចឹងទេតើ! បានជាមកដល់ភ្លាមក៏ហ៊ានឆ្លងចូលមករុករើផ្ទះខ្ញុំ នេះក៏ប្រហែលមកពីឯងទៅរៀនស្រុកគេយូរពេក ច្បាប់ទម្លាប់ស្រុកខ្លួនយ៉ាងណាក៏ភ្លេចអស់ដែរ!

ក្មេងប្រុសជំទង់ដូចជាមិនព្រមឲ្យភីណាបន្ទោសបងស្រីខ្លួនសោះ គេពោលតបវិញភ្លាម៖

-គាត់ឆ្លងមកមើលខ្មោចទេ! ពួកយើងគ្មានចិត្តថាមករំខានផ្ទះបងទេ យើងចង់ឃើញខ្មោចចង់ថតខ្មោច រួចហើយនឹងត្រឡប់ទៅវិញភ្លាម!

ភីណានៅស្ងៀមដៀងភ្នែកសម្លឹងមើលទៅបងប្អូនគេទាំងពីរ ឬមួយថានោះគឺជាការពិតដែលកប់ក្នុងអាថ៌កំបាំង?

នាងពោលសួរទៅកាន់ពួកគេ៖

-ឥឡូវនេះជួបខ្មោចហើយនៅ? បើឲ្យខ្ញុំនិយាយវិញ គឺបងប្អូនពីរនាក់ឯងនេះហើយជាខ្មោចយប់អធ្រាត្រហ៊ានផ្លោះរបងឆ្លងមកផ្ទះខ្ញុំ ឯងចង់ធ្វើឲ្យខ្ញុំលោះព្រលឹងមែនទេ!

ស្រីក្មេងរូបនោះលូកដៃមកចាប់កដៃភីណាដោយអាការស្និទ្ធស្នាលប្រៀបបីដូចជាមិត្តភ័ក្តិជិតស្និទ្ធតាំងតែពីពេលមុនមកអញ្ចឹង នាងពោលខ្សឹបៗប្រាប់ក្រមុំម្ចាស់បន្ទប់៖

-នែ៎មិនដឹងមែន ឬក៏ធ្វើពុតទេ? នៅជុំវិញទីនេះអ្នកណាក៏ឮនិយាយពីរឿងផ្ទះនេះដែរ!

ភីណាក្រឡាប់ភ្នែករិះគិត នាងយល់ថាដូចជាមានអារម្មណ៍ជឿសម្ដីពួកគេវិញបន្តិចម្ដងៗ ប៉ុន្តែនាងនៅធ្វើជាមិនទាន់យល់ដោយបន្លឺសួរវិញ៖

-និយាយពីផ្ទះខ្ញុំ ផ្ទះខ្ញុំមានរឿងអ្វីឲ្យពួកគេនិយាយ? ខ្ញុំទើបនឹងរើមកនៅទេមិនដែលមានរឿងជាមួយអ្នកណាសោះ...ហេតុអ្វីក៏....

និស្សិតស្រីរូបនោះបើកភ្នែកធំៗ និយាយកាត់សម្ដីក្រមុំម្ចាស់បន្ទប់៖

-ផ្ទះឯងមានខ្មោចណ៎ា! រឿងនេះគេនាំគ្នានិយាយតាំងពីឯងមិនទាន់រើមកនៅម៉្លេះ!

ភីណាផ្ទុះក្ដីសង្ស័យជាស្រេចទៅហើយ ប៉ុន្តែនាងនៅធ្វើជាពោលតបធ្វើហី៖

-មែនអី? ចុះម៉េចក៏ខ្ញុំនៅទីនេះ មិនដែលជួបខ្មោច?

ក្មេងប្រុសជំទង់ដែលឈរឆ្ងាយពីនាងទាំងពីរនោះលូកមាត់តបវិញភ្លាមដែរ៖

-បងគង់តែជួបទេ! ផ្ទះបងមានខ្មោចមែន ខ្ញុំនិងបងនេត្របានឃើញអម្បាញ់មិញ ខ្ញុំមានទាំងបានលួចថតបានរូបខ្មោចផង!

ភីណាផ្លាស់ទឹកមុខ នាងដៀងភ្នែកសញ្ជឹងគិត ភ្លាមនោះនិស្សិតស្រីដែលកំពុងចាប់ដៃនាងនៅឡើយ លាន់មាត់ពោលភ្លាមដែរ៖

-មែនណ៎ា! វាចេញពីបន្ទប់ខាងឆ្វេងនោះហើយ ហើយចូលទៅបន្ទប់ចុងនោះ!

ភីណាសម្លឹងមុខក្មេងស្រីម្ចាស់សម្ដី ហាក់ដូចជាចង់មើលឲ្យធ្លុះថាតើនាងនិយាយពិតឬបោកប្រាស់ ទោះក្នុងចិត្តកំពុងកើតសង្ស័យថាពិតច្រើនជាងកុហកក៏ដោយ។ លូកដៃមួលសោទ្វារបន្ទប់ អូសដៃភីណាឲ្យអើតសម្លឹងទៅក្រៅ នាងលូកដៃចង្អុលប្រាប់ដោយពោលញាប់ស្មេរ៖

-ខ្ញុំ និងប្អូនខ្ញុំឃើញមែន! វាចេញពីបន្ទប់ខាងឆ្វេងនោះ រួចហើយចូលទៅបន្ទប់ចុងនោះ ប៉ុន្តែវាអត់មានដើរទេ គឺបណ្ដែតខ្លួនណ៎ា!

ភីណាសម្លឹងទៅតាមបន្ទប់ខាងឆ្វេងតាមដែលនិស្សិតស្រីនោះចង្អុលប្រាប់ ទីនោះគឺជាបន្ទប់វត្ថុបុរាណដែលខ្លួននៅចាំថាកាលពីពេលយប់ដែលមានភ្លៀងធ្លាក់នោះ ខ្លួន និងបងថ្លៃស្រីបានឡើងមកកាន់ទីនោះ ហើយបានទាំងប្រទះឃើញបុរសមុខចម្លែកពីរនាក់គួរឲ្យខ្លាចទៀតផង រីឯបន្ទប់ខាងចុងដែលនិស្សិតស្រីចង្អុលថាស្រមោលខ្មោចបណ្ដែតខ្លួនចូលទៅកាន់ទីនោះការពិតគឺជាបន្ទប់របស់បងប្រុសនាងដែលនាងដឹងថាពេលនេះគឺបងថ្លៃរបស់ខ្លួនកំពុងសម្រាកនៅក្នុងនោះនៅឡើយ។

នាងងាកទៅសួរនិស្សិតស្រីក្បែរខ្លួន ដោយខ្វល់ខ្វាយ៖

-ឯងឃើញមែន ឬក៏និយាយលេងទេ? នោះជាបន្ទប់របស់បងប្រុសខ្ញុំទេតើ! ខ្មោចឯណាទៅចូលក្នុងនោះ?

និស្សិតស្រីរូបនោះតបវិញដោយក្ដីជឿជាក់៖

-មិនមែនភ្នែកខ្ញុំម្នាក់ឯងទេ! ប្អូនខ្ញុំទៀត វាក៏បានឃើញដែរ ឯងសួរវាចុះ?

ភីណាស្ទុះចូលមកក្នុងបន្ទប់វិញ ដោយរុញទ្វារបិទយ៉ាងប្រញាប់! ទ្រូងលោតញាប់រន្ថើនលើសមុនទៅទៀត កាលបើនាងពិចារណាចូលដល់រឿងបងថ្លៃស្រីរបស់ខ្លួន នាងដៀងភ្នែកសម្លឹងទៅបងប្អូនគេទាំងពីរដែលកំពុងស្ថិតនៅក្នុងបន្ទប់ជាមួយខ្លួនដែរ នាងឃើញគេទាំងពីរកំពុងបើកភ្នែកមូលក្រឡង់សម្លឹងផ្ដោតមកខ្លួនដែរ សភាពតានតឹងដែលគប់ក្នុងចិត្តយ៉ាងលំបាកលំបិននោះ បានចាក់អង្រួនចិត្តភីណាឲ្យលាន់មាត់ទៅកាន់ពួកគេទាំងមិនដឹងខ្លួន៖

-ឯងទាំងពីរដែលឮថាមនុស្សដាច់ខ្យល់ស្លាប់ហើយបែរជារស់ឡើងវិញដែរទេ?

ក្មេងប្រុសជំទង់នៅចំហមាត់បញ្ចេញទឹកមុខភ្ញាក់ផ្អើល ប៉ុន្តែវាបន្លឺតបមកកាន់ភីណា៖

-មនុស្សស្លាប់រស់វិញ កាលនៅអាមេរិកធ្លាប់ឃើញកាសែតចុះផ្សាយដែរ ប៉ុន្តែរស់វិញនោះលែងជាមនុស្សទៀតហើយ គឺខ្មោចឆៅណ៎ា!

ភីណាបើកភ្នែកធំៗរបៀបតក់ស្លុត នាងពោលសួរដាច់ៗ៖

-ដូច...ដូចក្នុងកុនអញ្ចឹងមែនទេ?

គេទាំងពីរនាក់បងប្អូនមិនបានឆ្លើយតបនឹងនាងក្រមុំទេ គេបែរជាបញ្ចេញទឹកមុខស្លន់ស្លោពោលជាមួយគ្នាដោយកាយវិការឆ្លេឆ្លា៖

-ស្លាប់ហើយ! ម៉ោងប៉ុន្មានហើយហ្ន៎? ប៉ាបិទទ្វារហើយឬនៅ យើងធ្វើម៉េចបានចូលផ្ទះទៅ?

ភីណាសម្លឹងទៅបងប្អូនគេទាំងពីរដែលកំពុងអូសដៃគ្នាប្រញាប់ប្រញាល់ចាកចេញពីបន្ទប់.... នាងឮនារីជាបងនោះពោលមកកាន់ខ្លួន៖

-លាសិនហើយ ! យប់ហើយពួកខ្ញុំត្រូវត្រឡប់ទៅវិញទើបបាន ខ្ញុំទៅសិនហើយណ៎ា? ថ្ងៃក្រោយជួបគ្នា!

ពួកគេសសៀរខ្លួនចាកចេញទៅ ភីណានៅឈរទ្រឹងមាត់ទ្វារបន្ទប់ សំណួរមួយលេចឆ្លៀតក្នុងចិត្តនាង៖

-ពួកឯងទៅបាត់ហើយ ចុះខ្ញុំគិតយ៉ាងម៉េច?

ភាគទី៨

មាណវីដៀងភ្នែកសម្លឹងទៅកាន់មាត់ទ្វារបន្ទប់វត្ថុបុរាណ និងមាត់ទ្វារបន្ទប់បងប្រុសខ្លួន នាងទទួលអារម្មណ៍ថាខ្លួនដូចជាព្រឺរងាយ៉ាងម៉េចមិនដឹងទេ ស្រស់ស្រីស្ទុះចូលមកក្នុងបន្ទប់វិញបិទទ្វារគ្រឹបយ៉ាងរហ័ស។

នាងស្ទុះមកអង្គុយលើគ្រែ ដណ្តប់ភួយដល់ត្រឹមក បើកភ្នែកភ្លឹះៗរិះគិតចុះឡើងតែម្នាក់ឯង ម៉េចក៏អ្នកជិតខាងនាំគ្នាខ្លាចរអាផ្ទះនេះហើយនិយាយនឹងគ្នាថាទីនេះមានខ្មោច? គេដឹងរឿងនេះមកពីណា? ធ្លាប់ឃើញខ្មោចពីកាលណា? បងប្អូនពីរនាក់អម្បាញ់មិញ និយាយថាឃើញខ្មោចបណ្តែតខ្លួនពីបន្ទប់មួយទៅបន្ទប់មួយ តើគេនិយាយពិតឬក៏មិនមែន? ប៉ុន្តែបើគេមិនជឿងឆ្ងល់ពីរឿងខ្មោចទេនោះ យប់អធ្រាត្របែបនេះហើយ តើចូលមកធ្វើអ្វី?

នាងក្រមុំរលឹកពីហេតុការណ៍ប៉ុន្មានម៉ោងមុនមកនេះ តាំងពីខ្លួនបានឮសម្រិបជើងរត់ចុះឡើង បានឃើញស្រមោលចម្លែកខ្លួនបានស្រែកភ្ញាក់អស់អ្នកនៅបម្រើ ប៉ុន្តែចុះម៉េចក៏បងថ្លៃស្រី ដែលសម្ងំសម្រាន្តក្នុងបន្ទប់រហូតនោះ មិនមានឃើញភ្ញាក់ផ្អើលឈានចេញពីបន្ទប់មកក្រៅមួយជំហានណាសោះយ៉ាងនេះ? ម៉េចគ្រាន់តែគេង ក៏ដូចមនុស្សស្លាប់ដែរ?

ស្រស់ស្រីងើបមុខសម្លឹងទៅទ្រនិចនាឡិកាដែលចង្អុលដល់ម៉ោងជិត "ដប់ពីរ" ទៅហើយ មិនទាន់ឮសូរឡានបងប្រុសខ្លួនត្រឡប់មកផ្ទះវិញនៅឡើយ នាងដឹងថាបើចេះតែរស់ក្នុងសភាពភិតភ័យរបៀបនេះតទៅទៀត មិនយូរទេ ទោះជាខ្លួនមិនឆ្កួតក៏មុខជាក្លាយជាឆ្កួតមែនទែនមិនខាន!

នាងប្រឹងសម្ងំបិទភ្នែក ប៉ុន្តែនៅតែមិនលក់សោះ ឬមួយថាឲ្យតែយប់កាលណា ត្រូវតែប្រើថ្នាំងងុយគេង? បើចេះតែយ៉ាងនេះរហូតទៅ តើនាងទ្រាំទ្របានដល់ពេលណាទៅ?

នាងក្រមុំអង្គុយត្របោមជង្គង់លើគ្រែដោយមួហ្មង តាមពិតផ្ទះធំ! មើលពីក្រៅទៅដូចជាកក់ក្តៅណាស់ប៉ុន្តែ តើមានអ្នកណាដឹងទេថា លើផ្ទះធំដាច់គេនេះ តរុណីរូបនេះ កំពុងអង្គុយមួហ្មងខ្វះភាពកក់ក្តៅខុសពីគេឯងរាល់គ្នាដែលកំពុងលង់លក់យ៉ាងស្កប់ស្កល់ហើយសុខសាន្ត។

ពេលវេលាចេះតែកន្លងទៅ ប៉ុន្តែភីណានៅតែស្វាងថៃសដដែល ភ្លាមនោះនាងស្រមៃស្វាត់ៗតែឯងថា ឯក្រៅទ្វារបន្ទប់ខ្លួន បងថ្លៃដែលស្លាប់ហើយរស់វិញយ៉ាងចម្លែកនោះ កំពុងឈរញញឹមត្រជាក់ស្រឹបប្រកបដោយភាពព្រឺព្រួច នាងចាប់ផ្តើមព្រឺក្បាលសំពោង សសៀរខ្លួនម្តងបន្តិចទៅកាន់ជ្រុងជញ្ជាំង ដណ្តប់ភួយផង ប្រឹងបិទភ្នែកបំផ្លាញអារម្មណ៍ស្រមៃរបស់ខ្លួនឲ្យបែកខ្ញែកកុំឲ្យនឹកគិតដល់មនុស្សចម្លែកនោះតទៅទៀត។

ភ្លាមនោះដែរ សូរម៉ាស៊ីនឡានឯខាងក្រោមផ្ទះដាស់អារម្មណ៍ ភីណាឲ្យគ្រេកអរ បើកភ្នែកវិញភ្លាម ដោយនឹកក្នុងចិត្តថាបងប្រុសខ្លួនត្រឡប់មកវិញហើយ។

សភាពភ័យខ្លាចទាំងប៉ុន្មាននឹងត្រូវរលាយបាត់ក្នុងពេលនេះ យប់នេះរួចខ្លួនហើយ ប៉ុន្តែនៅយប់ស្អែក ខានស្អែកទៀត?

## វគ្គទី៤

## សម្តី និង ការពិត

ស្នូរទូរសព្ទរោទ៍ញាប់រន្ថើនលើដំណេក ភីណាបើកភ្នែកព្រឹមៗសម្លឹងជុំវិញខ្លួន នាឡិកាប៉ោលលើជញ្ជាំងចង្អុលចំលេខ៧ហើយ នាងក្រោកខ្លួនអង្គុយដោយលើកដៃជ្រោងសក់ទាំងអស់ឲ្យទៅក្រោយ ទាំងក្បាលឈឺខ្មោកៗ ណាមួយដៃជើងក៏រសេះរសោះអស់កម្លាំងដែរនាងមិនឆ្ងល់ទេ នាងដឹងថាក៏បណ្តាលមកតែពីខ្លួនគេងមិនគ្រប់គ្រាន់អញ្ចឹងហើយទើបក្រោកពីគ្រែយ៉ាងដូច្នោះ។

ទូរសព្ទលើដំណេកនៅតែរោទ៍មិនឈប់ នាងលូកដៃទៅលើគ្រែមកស្តាប់៖

-អាឡូ! អ្នកណា?

សំឡេងមនុស្សជិតស្និទ្ធម្នាក់លាន់មកលាយដោយសូរសំឡេងសើចស្រាលៗ៖

-អាល័យយល់សប្តិឃើញអី? ម៉ោង៧ហើយ! នៅឈឺមិនទាន់ទៅសាលាកើត ក៏មិនត្រូវទម្លាប់គេងជ្រុលដែរ!

ដឹងថាវិទូគេមកចាំនៅខាងក្រោមហើយ ស្រស់ស្រីលើកដៃម្ខាងឈ្លីក្បាលដើម្បីបំបាត់ការឈឺចាប់ខ្លះ នាងតបបណ្តើរដោយទឹកមុខមិនសូវស្រស់៖

-បងចាំបន្តិចសិនទៅ ខ្ញុំចុះទៅឥឡូវហើយ!

នាងបិទទូរសព្ទច្រត់ដៃក្រោកពីគ្រែ កុំថាឡើងតែក្បាលដែលវិលខ្វាល់ សូម្បីតែជើងក៏ល្វើយស្ទើរតែលើកដាក់មិនរួចដែរ នាងក្រមុំដើរមួយៗចូលទៅបន្ទប់ទឹក សម្លឹងមុខខ្លួនក្នុងកញ្ចក់ ចំជាគួរឲ្យភ្ញាក់ផ្អើលណាស់ ទោះជាមនុស្សប្រកបដោយរូបរាងផូរផង់យ៉ាងណា ក៏ត្រូវកប់សម្រស់បាត់អស់ហើយដែរ កាលបើផ្ទៃមុខស្លេកស្លាំងហើយល្វិតល្វៃយ៉ាងនេះ។ នាងលើកម្រាមស្ទាបផ្ទៃមុខដោយសម្លឹងផ្តោតទៅក្នុងកញ្ចក់ ទោះបីជាទឹកត្រជាក់ស្រឹបមកផ្សើមផ្ទៃមុខឲ្យបានស្វាងច្រើនជាងមុនខ្លះហើយក៏ដោយ ប៉ុន្តែភីណានៅតែមើលរូបខ្លួនឃើញថាមានស្ថានភាពប្រៀបដូចជាអ្នកជំងឺធ្ងន់ធ្ងរម្នាក់អញ្ចឹង។

នាងរៀបចំខ្លួនរួចរាល់ ចុះមកបន្ទប់ធំខាងក្រោមឃើញវិទូនៅអង្គុយអានកាសែត ប៉ុន្តែនៅមិនទាន់ឃើញបងប្រុសខ្លួននៅឡើយ នាងគិតថាយប់មិញមកដល់ផ្ទះយប់ជ្រៅពេក តាមមើលថ្មើរណេះគាត់មិនទាន់ក្រោកពីដំណេកនៅឡើយទេ។

មាណវីដើរចុះមកដល់ វិទូងើបមុខសម្លឹងមកកាន់នាង សភាពមិនស្រស់បស់របស់តរុណីក៏ត្រូវបានអ្នកកំលោះរូបនេះមើលឃើញមិនរំលងឡើយ គេលាន់មាត់ពោលសួរ៖

-យ៉ាងម៉េចហើយ? យប់មិញទូរទស្សន៍មានកម្មវិធីអ្វី ដូចគេងមិនឆ្អែតសោះ?

នាងក្រមុំដាក់បង្គុយទល់មុខនាយ ហើយឆ្លើយតបកំបុតឆ្គុយ៖

-រឿងខ្មោច!

វិទូនៅតែមានចេតនាចង់លលេង គេញញឹមបត់កាសែតទុកដោយបន្លឺសួរបន្ថែម៖

-ហើយខ្មោចមានចេញពីទូរទស្សន៍មកលងអត់ទេហ្នឹង?

ភីណាលូកដៃទាញកាសែតយកមកអានបណ្តើរ មាត់រអ៊ូបណ្តើរ៖

-មិនដឹងជាអ្នកណាទេ ពីម្សិលមិញថាទូរសព្ទមក!?

វិទូគិតថាតាមមើលទំនងជានាងង៉ក់ងរឿងដែលខ្លួនរវល់មិនបានទូរសព្ទរកនោះហើយមើលទៅ ទើបអ្នកខំញញឹម ពោលដោះសា៖

បងរវល់ទេតើ! មិនមែនមិនយកចិត្តទុកដាក់ជាមួយអូនឯណា? ប៉ុន្តែរកដកឃ្លាមិនបាន ឥឡូវអ៊ីចេះចុះ បងជូនទៅទិញអីវ៉ាន់ ទុកថារួចគ្នាចុះបានអត់?

ភីណាញញឹមតបដោយមិនមើលមុខកំលោះគូស្នេហ៍៖

-ប្រយ័ត្នតែដើរសុខៗ ស្រែកថាដល់ម៉ោងទៅបង្ហាញខ្លួននៅកន្លែងធ្វើការទៀត!

វិទូប្រញាប់ប្រញាល់ពោលតបភ្លាម៖

-អត់ទេ! យប់មិញមានក្តីថ្មី ធ្វើការដល់ភ្លឺ ព្រឹកនេះបានច្បាប់សម្រាកហើយ ក៏មករកអូនតែម្តងហ្នឹង!

ភីណាងើបមុខសម្លឹងគេ ជាក់ស្តែងគឺនាងកំពុងឈឺឆ្អាលចំពោះសុខភាពអ្នកកំលោះ គូបញ្ចាំចិត្តរូបនេះណាស់ ប៉ុន្តែនាងធ្វើជាពោលចំអន់៖

-ធ្វើការមួយយប់ទល់ភ្លឺផង? មើលមុខចុះ ស្រស់ជាងអូនទៅទៀត!

វិទូឱនមុខមកក្បែរនារីគូស្នេហ៍ អ្នកពោលតិចៗក្បែរនាង៖

-មិនជឿបងទេអ្ហស់! មើលថា Facebookទៅ យប់មិញចាប់ចោរបានមួយខ្សែដល់ទៅដប់បីនាក់ឯណោះ គ្រាន់តែសួរចម្លើយម្តងម្នាក់ៗហ្នឹង ស្ទើរតែមិនដឹងភ្លឺ ហ៊ុយ អស់កម្លាំងណាស់!

ភីណាសម្លក់ដោយគ្នាន់ក្នាញ់នាងឧទាន៖

-អញ្ចឹងរឹតតែមិនបាច់ទៅទិញអីវ៉ាន់ជាមួយបងហើយ វរៗ បងសម្រាន្តលក់នៅផ្សារ ធ្វើម៉េចទៅ?

អ្នកកំលោះផ្តេកខ្លួនទៅនឹងបង្អែកសាឡុងទាំងស្ងាបហ៊ាមៗ ភីណាពោលបន្តទាំងដៃបត់កាសែតទុក៖

-មិនបាច់ធ្វើប៉ូលិស មិនបានទេអ្ហេស៎? គ្មានបងក៏មិនខ្វះអ្នកចាប់ចោរដែរ ការងារអីគ្មានយប់គ្មានថ្ងៃ បើទំនេរក៏ទំនេរដោយទន់ខ្លួនដោយបើកភ្នែកមិនចង់រួច យ៉ាងនេះដដែលបងដូរការងារទៅ មិនបានសង្ហានឹងឯកសណ្ឋានប៉ូលិសហ្នឹងក៏មិនទាស់ខុសអ្វីដែរ!

វិទូធ្មេចភ្នែកផ្ដេកក្បាលនឹងបង្អែក ប៉ុន្តែបបូរមាត់នៅញញឹមស្រស់ បញ្ជាក់ថាគេនៅឮសម្ដីនាងក្រមុំដែរ គ្រាន់តែមិនឆ្លើយតបប៉ុណ្ណោះ ភីណាដកដង្ហើមធំពោលដោយដាក់កាសែតទុកទៅម្ខាង៖

-នៅហ្នឹងហើយ! អូនក្រោកទៅឆុងកាហ្វេឲ្យ! គួរឲ្យស្អប់ណាស់ ប្រាប់ឲ្យហើយកន្លែងនេះមិនអនុញ្ញាតឲ្យគេងលក់ទេ!

វិទូញញឹមស្រស់ បើកភ្នែកមកវិញសម្លឹងដំណើរនាងក្រមុំដែលដើរសំដៅផ្ទះចង្ក្រាន។ នៅឯណោះភីណារៀបចំឆុងកាហ្វេផង ចិត្តមួយអាណិតវិទូព្រួច នាងដឹងថាវិទូពេញចិត្តការងារនោះទោះបីថាវាលំបាកលំបិន គ្មានទទួលបានមកវិញនូវផលប្រយោជន៍អ្វីជាបុគ្គលក៏ដោយ ណាមួយនាងជាគូដណ្ដឹង អាចចាត់ថាជាគូទៅអនាគតរបស់គេ ទោះបីថាមិនសប្បាយចិត្តនឹងឲ្យគេធ្វើប៉ូលិស ក៏មិនហ៊ានរារាំងដែរ គ្រាន់តែពោលឲ្យឃើញគេហត់នឿយពេក ក៏ពោលរអ៊ូតាមចិត្តនឹកទៅ ប៉ុន្តែសេចក្ដីឈឺឆ្អាលអាណិតយកចិត្តនឹកទុកដាក់នោះវិញទេ ដែលច្រាលពេញដើមទ្រូង។

នាងឈរឆុងកាហ្វេបណ្ដើរ រិះគិតពីអ្នកកំលោះបណ្ដើរ ក៏ស្រាប់តែឮអ្នកបម្រើចំណាស់ពោលរអ៊ូដោយភ្ញាក់ផ្អើលក្បែរទូទឹកកក៖

-ស្លាប់ហើយ! បាត់សាច់គោទៀតហើយ! ដាក់នៅហ្នឹងច្បាស់ណាស់ ម៉េចក៏ចេះបាត់ទៅកើត?

ភីណាជ្រួញចិញ្ចើមបែរមកសម្លឹងអ្នកបម្រើចំណាស់ដែលកំពុងឱនរុករើទូទឹកកក នាងក្រមុំពោលសួរទាំងងឿងឆ្ងល់៖

-មីងអួន! បាត់សាច់ទៀតហើយអ្ហេស៎?

អ្នកបម្រើងាកមកតបទាំងទឹកមុខងឿងឆ្ងល់៖

-ទុកត្រង់ហ្នឹងច្បាស់ណាស់ ស្រាប់តែបាត់ទៅកើត!

ភីណាដើរទៅក្បែរគាត់ដោយមានកាន់ពែងកាហ្វេនៅនឹងដៃផង នាងសម្លឹងទៅក្នុងទូទឹកកកទាំងមាត់ពោលៈ

-រកឲ្យសព្វសិនទៅមីង!

អ្នកបម្រើរូបនោះប្រឹងរុករកបន្ត មួយខណៈក្រោយគាត់ងាកមកវិញតបដោយទឹកមុខមិនសប្បាយចិត្តៈ

-អត់ឃើញមែននាងតូច!

នាងក្រមុំជ្រួញចិញ្ចើម នាងពោលដោយអាការហួសចិត្តៈ

-អ្នកណាអីចង្រៃយ៉ាងនេះ? បើថាសត្វណាក៏វាមិនទំនង ព្រោះផ្ទះយើងគ្មានសត្វចិញ្ចឹមផង!

អ្នកបម្រើដឹងថាបណ្ដាលឲ្យនាងក្រមុំមិនសប្បាយចិត្តទៀតហើយ ម្ល៉ោះហើយគាត់ប្រឹងរៀបចំទឹកមុខឲ្យស្រួលបួលជាងមុនពោលទៅកាន់នាងៈ

-នាងតូច! ចាំខ្ញុំធ្វើអាហារផ្សេងសិនចុះ!

ភីណាឈ្ងោកមុខកាន់ពែងកាហ្វេដើរចេញបណ្ដើរ មាត់និយាយតបបណ្ដើរៈ

-មិនបាច់ទេមីង ខ្ញុំទៅញ៉ាំខាងក្រៅមួយថ្ងៃទៀតចុះ!

នាងក្រមុំដើរមកកាន់បន្ទប់ទទួលភ្ញៀវដោយទឹកមុខមិនរីករាយ។ នាងហុចពែងកាហ្វេទៅឲ្យអ្នកកំលោះ ទាំងនិយាយប្រាប់ៈ

-ឆាប់ពិសាកាហ្វេទៅ ព្រឹកនេះហាមគេង!

វិទូលូកដៃទទួលកាហ្វេមកកាន់ ភ្នែកសម្លឹងទៅកាន់ក្រមុំដែលកំពុងដាក់បង្គុយចុះទល់មុខខ្លួនដោយអាការដូចជាមិនសូវសប្បាយចិត្ត អ្នកពោលសួរទៅកាន់នាងភ្លាមៈ

-គ្រាន់តែឆុងកាហ្វេមួយពែង ក៏ធ្វើមុខមិនរីកទៅហើយ!

ភីណាតបទាំងជ្រប់មុខៈ

-អូនត្រូវគេងបង្អត់ណ៎ា! ឆាប់ៗទៅ ទៅញ៉ាំអីខាងក្រៅ!

វិទូក្រេបជាតិកាហ្វេដ៏ឈ្ងុយឆ្ងាញ់បន្តិចទើបសម្លឹងមកនាងក្រមុំសាជាថ្មី ដោយពោលមកកាន់នាងទាំងញញឹម៖

-ម្សិលមិញបាត់សាច់ ឥឡូវថ្ងៃនេះបាត់សាច់ទៀតហើយមែនទេ?

ភីណារអ៊ូដោយទឹកមុខមិនពេញចិត្ត៖

-មីងៗហ្នឹងគាត់ភ្លេចទិញក៏មិនដឹង ចេះតែថាបាត់ៗ ផ្ទះអត់មានឆ្កែឆ្មា តើធ្វើម៉េចអាចបាត់សាច់ទៅទៅកើត?

វិទូសើចស្រស់តបវិញភ្លាមដែរ៖

-បងថាយប់មិញអូនឃ្លានក៏ក្រោកចុះមកធ្វើញ៉ាំអស់ទៅ បើបាត់ក៏បាត់តែមួយថ្ងៃទេ ក៏មិនអាចបាត់រាល់ថ្ងៃអញ្ចឹងដែរ! អូនធ្វើញ៉ាំអស់ហើយ ភ្លេចតែខ្លួនឯងទេដឹង? អូនចូលចិត្តសាច់គោម៉្លឹងៗ អ្នកណាទុកចិត្តបាន!

ភីណាដឹងថាអ្នកកំលោះចង់ពោលលេងនឹងខ្លួនហើយ នាងសម្លក់គេទាំងពោលរអ៊ូ៖

-បងឯងទេដែលរវើរវាយអញ្ចឹងនោះ ខ្ញុំវិញមិនចេះភ្លេចភ្លាំងរបៀបហ្នឹងទេ! តោះឈប់និយាយទៅ ល្មមជូនអូនទៅរកអីញ៉ាំហើយ។

វិទូក្រោកពីបង្គុយ ដើរចេញមកក្រៅតាមពីក្រោយនាងក្រមុំគូស្នេហ៍។ អ្នកពោលទៅកាន់នាងដែលកំពុងរុញបើកទ្វាររបង៖

-ទៅត្រឹមដើមផ្លូវនោះទេអ្ហែស៎?

ភីណាឆ្លើយតបដោយមិនងាកក្រោយ៖

-ចា៎! យើងដើរទៅបានហើយ!

វិទូដើរមកក្បែរនាង គេអើតសម្លឹងទៅផ្លូវថ្នល់ដែលស្ងាត់ច្រៀប គេពោលប្រាប់ភីណា៖

-ម៉្ងៃនេះចម្លែកដែរ ព្រឹកព្រលឹមសោះក៏ស្ងាត់ច្រៀប!

ឮសម្តីគេ ភីណានឹកភ្នកទៅដល់រឿងចចាមអារ៉ាមដែលអ្នកនៅជុំវិញ ទីនេះគេបាននិយាយពីផ្ទះខ្លួន ភ្លាមនោះក៏នឹកឃើញដល់បងប្អូនស្រីប្រុសពីរនាក់ កាលពីយប់មិញបានលួចចូលមក

ក្នុងផ្ទះ ពួកគេប្រាប់ថាផ្ទះនៅជាប់ខាងស្ដាំដៃនេះដែរទេ។ នាងក្រមុំងើបមុខសម្លឹងទៅកាន់ភូមិគ្រឹះសង់របៀបអឺរ៉ុប តូចច្រឡឹងរុំព័ទ្ធដោយសួនផ្កាវីកស្គុះស្គាយជាប់គ្នានឹងរបងផ្ទះខ្លួន នាងសួរក្នុងចិត្តស្ងាត់ៗតែម្នាក់ឯង៖

-ពីរនាក់នោះកុហកទេដឹង? ផ្ទះនេះជាផ្ទះរបស់ពួកគេអ្ហេស៎? ប៉ុន្តែបើចង់ដឹងច្បាស់ ទាល់តែចូលទៅមើលទើបបាន!

គិតរួចភីណាស្ទុះស្ទាដើរសំដៅទៅមាត់ទ្វាររបងនោះភ្លាម នាងអើតសម្លឹងទៅក្នុងតាមចន្លោះរបង ប៉ុន្តែគ្មានឃើញស្រមោលមនុស្សម្នាក់សោះ មិនរវល់គិតច្រើននាងលូកដៃចុចកណ្ដឹងភ្លាម រីទូដែលទើបតែដើរមកដល់នោះពោលសួរទាំងងឿងឆ្ងល់៖

-គិតធ្វើអីហ្នឹង? ក្រែងថាទៅស្រស់ស្រូបអ្ហេស៎?

ភីណាងាកមកញញឹមស្រស់ដាក់អ្នកកំលោះដោយពោលប្រាប់៖

-អូននឹកឃើញភ្លាមៗនេះថា ចង់ចូលជួបមិត្តម្នាក់សិន! នែ៎ចាំអូននាំបងឲ្យស្គាល់គេណ៎ា!

ទ្វាររបងត្រូវបើកដោយដៃបុរសចំណាស់ មាឌស្ដើង ទឹកមុខស្លូតបូត សម្បុរខ្មៅ ឫកពាស័ក្តិសមជាអ្នកជនបទ គាត់បន្លឺសួរមកកាន់ភីណាដោយអាការគួរសម៖

-អត់ទោស! អ្នកនាងមានការអ្វីដែរ?

ភីណាគ្រាន់តែមើលភ្លាម ក៏ស្គាល់ថាគាត់ជាអ្នកថែសួនដែលខ្លួនឧស្សាហ៍ប្រទះភ្នែកដែរ ប៉ុន្តែគាត់បែរជាមិនស្គាល់នាងទៅវិញ នាងញញឹមស្រស់ដើម្បីបង្កឲ្យគេនូវអារម្មណ៍ល្អចំពោះខ្លួនដោយបន្លឺតប៖

-ចាស៎ពូ! ក្រែងទីនេះ មាននិស្សិតស្រីម្នាក់ទើបតែត្រឡប់មកពីបរទេសតើមែនទេ?

បុរសចំណាស់សម្លឹងមកនាងក្រមុំ និងអ្នកកំលោះបណ្ដើរ ឆ្លើយតបបណ្ដើរដោយអាការស្លូតបូត៖

-បាទ! នាងតូចនេត្រ! អ្នកនាងរកនាងតូចនេត្រតើមែនទេ? នាងតូចខ្ញុំទើបត្រឡប់មកពីបរទេសមែន!

ភីណាញញឹមស្រស់ជាងមុនទៅទៀតកាលបើបានឮចម្លើយនេះ នាងដឹងថាពីរនាក់បងប្អូននោះប្រាកដជាមិនមាននិយាយកុហកទេ នាងតបទៅកាន់បុរសចំណាស់បន្ថែម៖

-ជម្រាបទៅអ្នកនាងនេត្រផង ថាខ្ញុំជាអ្នកជិតខាងសុំជួប!

បុរសចំណាស់បញ្ចេញទឹកមុខភ្ញាក់ផ្អើល គាត់រអ៊ូតាមពីក្រោយពាក្យនាងក្រមុំ៖

-អ្នកជិតខាង?

មិនរង់ចាំយូរឡើយ ស្រស់ស្រីប្រញាប់ប្រញាល់ពោលទៅកាន់គាត់វិញ៖

-ចាស៎! ផ្ទះខ្ញុំនៅជាប់គ្នានេះទេ!

និម្មិតណាបានឮសម្ដីនេះ បុរសអ្នកថែសួនងាកយ៉ាងរហ័សសម្លឹងទៅរកគេហដ្ឋានធំចង្គ្រុងដែលនៅជាប់របងខាងឆ្វេងដៃ គាត់ងាកមកសម្លឹងភីណា និងវិទូវិញតបដោយពោលគួរសម៖

-សូមអញ្ជើញចូល!

**ភាគទី៩**

ភីណាដើរមួយៗចូលទៅក្នុងបរិវេណគេហដ្ឋាន ដែលសំបូរទៅដោយក្លិនផ្កាគ្រប់បែបយ៉ាងហើរមកប៉ះនាសាឈ្ងុយឈ្ងប់គួរឲ្យត្រជាក់ចិត្ត។ កំលោះក្រមុំភ្ញៀវតូចមធ្យមមួយ ដែលប្រកបទៅដោយសណ្ដាប់ធ្នាប់ និងការរៀបចំយ៉ាងគាប់ភ្នែក បុរសចំណាស់បង្ហាញទៅកាន់សាឡុងមួយកំផ្លេ ដែលស្ថិតនៅឯជ្រុងខាងកើត ដោយពោលប្រាប់៖

-លោកក្មួយ! អ្នកនាងអញ្ជើញអង្គុយ! ខ្ញុំប្រាប់គេឲ្យឡើងទៅជម្រាបអ្នកនាងតូច!

បុរសចំណាស់បែរខ្លួនដើរសំដៅចូលទៅខាងក្នុងភីណា និងវិទូអង្គុយលើសាឡុង រំពៃមើលបរិយាកាសដ៏មនោរម្យនៃបន្ទប់ទទួលភ្ញៀវនៃភូមិគ្រឹះ ដែលត្រូវបានរៀបចំតាមលក្ខណៈទំនើបគួរឲ្យចង់គយគន់ ខណៈនោះស្ត្រីវ័យក្មេងកណ្ដាលម្នាក់ផ្សេងក្នុងឫកពាររបៀបជាអ្នកបម្រើ ទឹកមុខស្លូតបូតនៅលើដៃមានកាន់ថាសទឹកពីរកែវ មកជាមួយផង គាត់ដើរស្រាលៗថ្នមៗតម្រង់មកកាន់ភ្ញៀវកំលោះក្រមុំទាំងពីរ ដោយដាក់កែវទឹកអញ្ជើញភ្ញៀវរួមជាមួយនឹងប្រយោគគួរសម៖

-អ្នកនាង! លោកក្មួយ! អញ្ជើញពិសាទឹករង់ចាំសិនចុះ!

ភីណាញញឹមស្រស់ពោលតប៖

-ចាស៎! មិនអីទេ!

អ្នកបម្រើចំណាស់មិនទាន់ដើរចូលទៅវិញផង ស្រាប់តែលាន់ឮសូរសព្ទស្រួយស្រើបប្រកបដោយអាការរីករាយពីជាន់ខាងលើ៖

-យីអើ! ភ្ញៀវពិសេសទេតើ!

ភីណាងើបមុខសម្លឹងទៅលើជណ្តើរតាមដែលឮសូរសំឡេងមកខ្លួន ប៉ុន្តែចម្លែកនោះគឺថាសម្លៀកបំពាក់នារីនិស្សិតបរទេសលើកនេះ មិនមែនរឹបរាងអាក្រក់មើលដូចកាលពីយប់នោះទេ នាងស្លៀកសំពត់ផ្កាដែលផ្គុំឡើងពីសាច់ក្រណាត់ទន់រលោង និងអាវពណ៌ខ្មៅ បញ្ចេញសម្រស់គួរឲ្យគយគន់។ នាងឈានញាប់ស្មេរចុះមកពីជណ្តើរដោយអាការរួសរាយ សម្លឹងមកភ្ញៀវទាំងពីរ។

ភីណា និងវិទូក្រោកពីបង្គុយទទួលដំណើរមកដល់របស់អ្នកម្ចាស់ផ្ទះ ល្មមពោលឮនិស្សិតនារីរូបស្អាតលាន់មាត់ប្រាប់៖

-អញ្ជើញអង្គុយ! អញ្ជើញអង្គុយ!

ភីណាឆ្លៀតឱកាសនេះក៏ណែនាំវិទូឲ្យបានស្គាល់តែម្តង៖

-នេះបងវិទូគូដណ្តឹងខ្ញុំ!

នារីនិស្សិតរូបស្អាត ថ្វីត្បិតថានាងមានអាការរួសរាយរាក់ទាក់តាមបែបយុវវ័យទាន់សម័យ ក៏ប៉ុន្តែនាងក៏នៅចៀសមិនផុតពីលើកដៃផ្គុំជម្រាបសួរម្នាក់កំលោះតាមច្បាប់ពីបុរាណដែរ អ្នកទាំងបីគួរសមនឹងគ្នាទៅវិញទៅមក ក៏ស្រាប់តែឮសូរសំឡេងធំគ្រលរស្រែកមកពីខាងលើដោយអាការមិនសប្បាយចិត្ត៖

-ពូកន! ពូកន! ឡើងមកណេះសិន!

គ្រាន់តែស្តាប់សំឡេង ក៏ភីណាស្គាល់ថាជាសំឡេងរបស់ក្មេងប្រុសជំទង់ដែលកាលពីយប់បានលួចចូលមកក្នុងផ្ទះនោះដែរ។ នាងងើបមុខសម្លឹងទៅជណ្តើរឡើងទៅជាន់ខាងលើសាជាថ្មី នាងឃើញក្មេងជំទង់រូបនោះប្រកបដោយទឹកមុខមិនសប្បាយចិត្តណាមួយលើខ្លួននៅ

ស្លៀកសំលៀកបំពាក់រាត្រីនៅឡើយ គេឈានចុះមកបណ្ដើរបើកភ្នែកគ្រលួងសម្លឹងចុះមក ខាងក្រោយបណ្ដើរ តាមមើលទំនងជាវត្តមានរបស់នាងក្រមុំ និងអ្នកកំលោះវិទូធ្វើឲ្យគេភ្ញាក់ ផ្អើលហើយមើលទៅ គេចុះមកដល់ភ្លាម នារីនិស្សិតជាបងលាន់មាត់ពោលភ្លាមដែរទៅកាន់ គេ៖

-អូនឯងមើលចុះ សំណាង! អ្នកណាមកលេងយើង?

ក្មេងប្រុសជំទង់សម្លឹងមកភ្ញៀវបណ្ដើរ ទឹកមុខមិនស្រស់ថ្លារបស់គេបានផ្លាស់ប្ដូរជាបណ្ដើរៗ គេលើកដៃជម្រាបសួរភ្ញៀវទាំងពីរ ទាំងញញឹមញញែម៖

-បងទាំងពីរទេ? កម្រណាស់ដែលបានបងចូលមកលេងបែបនេះ សូមទោសដោយខ្ញុំមិនបាន ដឹងមុន! អញ្ជើញអង្គុយ!

នារីនិស្សិតជាបងលាន់មាត់ពោលតាមពីក្រោយប្អូន៖

-អញ្ជើញអង្គុយ អញ្ជើញអង្គុយ!

ភីណា និងវិទូដាក់បង្គុយទៅលើសាឡុងសាជាថ្មី នារីនិស្សិតក៏អង្គុយចុះទស់គេទាំងពីរដែរ ប៉ុន្តែនាងនៅងើបមុខសម្លឹងទៅប្អូនប្រុសដោយពោលសួរ៖

-អម្បាញ់មិញរអ៊ូរកពូកនរឿងអី?

ក្មេងប្រុសជំទង់ អេះក្បាលញញឹមសម្លឹងបងស្រីបន្តិច សម្លឹងភ្ញៀវបន្តិចទើបឆ្លើយតប៖

-អត់ អត់អីទេ បំពង់ទឹកខូច ខ្ញុំចង់ហៅពូកនឲ្យរកជាងមកមើល!

នារីនិស្សិតនេត្រ សើចស្ងួតរបៀបហួសចិត្ត នាងគ្រវីក្បាលយឺតៗ ដោយមាត់ពោល៖

-រឿងប៉ុណ្ណឹងសោះ ក៏ឡូឡាឲ្យភ្ញាក់ផ្អើលពេញផ្ទះដែរ!

ក្មេងប្រុសជំទង់នៅស្ងៀមលែងតប គេបម្រុងបែរខ្លួនដើរទៅខាងលើវិញទៅហើយក៏គាប់ជួន ពេលនោះ វិទូងើបមុខសម្លឹងមកគេដោយបន្លឺប្រាប់ទាំងញញឹម៖

-អ៊ីចេះចុះ! រឿងបំពង់ទឹកបងក៏ធ្លាប់ធ្វើពីរបីដងហើយដែរ ចាំបងជួយមើលឲ្យឯងចុះ! ក្រែង លោមិនបាច់ហៅជាង!

ក្មេងប្រុសទីទើរ ហើយបងស្រីគេនិយាយរារាំង៖

-អ្ហូ! ម៉េចកើត?! បងប្រុសជាភ្ញៀវ ឲ្យមកជួសជុលទុយយោកើតដែរ? មិនកើតទេ! ឲ្យពូកនហៅជាងទៅ!

-មិនអីទេ! តោះនាំបងទៅ!

ក្មេងជំទង់បង្ហាញក្តីរីករាយលើផ្ទៃមុខ គេសើចស្រស់ឆ្លើយតបភ្លាម៖

-បាទនៅខាងលើ! អញ្ជើញឡើងមកតាមខ្ញុំ!

ពួកគេទាំងពីរឡើងតម្រង់ទៅជាន់ខាងលើ នារីនិស្សិតងាកមកកាន់ភីណា នាងវាចាដោយញញឹមស្រស់៖

-កុំប្រកាន់ណ៎ា! ប្អូនប្រុសខ្ញុំនេះមិនដឹងខុសត្រូវអីទេ ទាំងព្រឹកព្រលឹមក៏ហ៊ានរំខានគូដណ្តឹងឯងដែរ!

ភីណាសើចស្រស់ ឧទានតបវិញភ្លាម៖

-កុំខ្វល់ច្រើន មនុស្សនោះសប្បាយចិត្តជួយគេណាស់!

នារីនិស្សិតងក់ក្បាលដោយអាការរបៀបស្ងើចសរសើរ៖

-តាមស្តាប់ គាត់ជាមនុស្សល្អណាស់! អូនែ៎ ចាំខ្ញុំធ្វើអាហារពេលព្រឹកដោយផ្ទាល់ដៃទទួលអ្នកទាំងពីរចុះណ៎ា!

ភីណាប្រញាប់ប្រញាល់ពោលឃាត់ភ្លាម៖

-កុំអី ខ្ញុំមកនេះមកសួរឯងពីរឿងខ្មោចនោះតើ!

នារីម្ចាស់ផ្ទះញញឹមស្រស់ ក្រោកពីសាឡុង បន្លឺមកកាន់ភីណា៖

-កុំអាលនិយាយដល់រឿងខ្មោចនោះ នៅមានពេលច្រើនណាស់ ណាមួយគូដណ្តឹងឯងគាត់ជួយធ្វើការបំពង់ទឹកឲ្យប្អូនប្រុសខ្ញុំដែរ ពេលចុះមកវិញមុខតែឃ្លានហើយ! អង្គុយលេងទៅខ្ញុំចូលទៅធ្វើតែមួយភ្លែតទេ!

ភីណាក្រោកឈរពោលឃាត់នារីម្ចាស់ផ្ទះដែលប្រកបដោយភាពស្និទ្ធស្នាលរូបនេះ៖

-ធ្វើអញ្ចឹង ដូចជាមិនសមសោះ!

នារីម្ចាស់ផ្ទះ សើចស្រស់ពោលតបទាំងចាប់អង្អែលដៃភីណា៖

-ឯងកុំបែងចែកពេកអី យើងជាអ្នកជិតខាងគ្នា ជិតស្និទ្ធបន្តិចក៏មិនទាស់ខុសអីដែរ!

ភីណាញញឹម នាងរិះគិតស្ងាត់ក្នុងចិត្ត ចាប់តាំងពីខ្លួនរើមកនៅទីនេះរាប់ទៅ គឺជាងមួយខែហើយមិនដែលបានអ្នកជិតខាងណានិយាយរាក់ទាក់ឲ្យបានពេញមាត់នៅឡើយ ខុសប្លែកតែនារីនិស្សិតនេះជួបនាងភ្លាមក៏បង្កនូវអារម្មណ៍ល្អមួយភ្លាមដែរ។

គ្មានរឿងអីដែលថាខ្លួនគួរឆ្មើងកន្ទ្រើងមិនទទួលយកទឹកចិត្តស្មោះត្រង់របស់គេនោះ គិតឃើញដោយសុទិដ្ឋិយ៉ាងនេះហើយ ទើបនាងក្រមុំយើងឆ្លើយតបទៅកាន់នារីនិស្សិតដោយទឹកមុខស្រស់ស្រាយ៖

-ខ្ញុំឈ្មោះភីណា ខ្ញុំមិនទាន់ស្គាល់ឈ្មោះឯងនៅឡើយ តែដូចជាឮពួកគេ ហៅថា ថា...។

នាងក្រមុំភីណាមិនទាន់បានបញ្ចប់ឃ្លាប្រយោគរបស់ខ្លួននៅឡើយ តែឮនាងនិស្សិតឆ្លើយកាត់ភ្លាម៖

-ឯងហៅខ្ញុំថានេត្រៗចុះ ឈ្មោះដើមខ្ញុំគឺនេត្រាទេ ប៉ុន្តែមិត្តភ័ក្តិសុទ្ធតែហៅនេត្រៗអញ្ចឹងទៅហើយ ឯប្អូនខ្ញុំគេឈ្មោះសំណាង... អូនែ៎ អាល័យតែនិយាយ ខ្ញុំចូលទៅចង្រ្កានសិន ឆាប់ទេ អង្គុយលេងសិនចុះណ៎ា!

ភីណាបង្ហាញទឹកមុខស្រស់ស្រាយតបទៅកាន់នាងក្រមុំរូបនោះវិញភ្លាមដែរ៖

--ខ្ញុំចូលទៅធ្វើជាមួយដែរចុះ!

ក្រមុំនិស្សិតសម្លឹងមកភីណា នាងពោលសួរវិញដោយរបៀបចង់អស់សំណើច៖

-ឯងហ្នឹង? ឯងចេះដែរទេ រកទៅជួយខ្ញុំហ្នឹង? តាមមើលមិនចាំបាច់ទេដឹង! ឯងអង្គុយលេងនៅហ្នឹងចុះ! ឬក៏ខ្ញុំរកសៀវភៅឲ្យឯងអានចុះ!

ភីណាបើកភ្នែកក្រឡង់ពោលតបភ្លាមមិនសុខចិត្ត៖

-មើលងាយ? រាងខ្ញុំដូចមនុស្សមិនចេះការងារចង្រ្កានសោះ ?

នេត្រតបវិញទាំងសើចខឹកៗ៖

-រាងឯងមិនដូចទេ ប៉ុន្តែឯងហ្នឹងទេដែលដូច! ពេលខ្ញុំចូលផ្ទះឯងឮឯងប្រើអ្នកផ្ទះឲ្យចៀនសាច់គោឲ្យទៀតមែន អត់?

ភីណាក្តាប់មាត់តបវឹង៖

-យប់នោះខ្ញុំខ្ជិលធ្វើសោះហ្នឹង! តាមពិតខ្ញុំចៀនបានល្អជាងមីងៗផង!

នារីនិស្សិតសើចដោយហួសចិត្ត នាងបន្លឺសួរ៖

-ចៀនពងទាមែនទេ?

ភីណាដឹងថាមិនអាចនិយាយឲ្យឈ្នះនាងក្រមុំរូបនេះបានឡើយ ម្ល៉ោះហើយនាងពោលកាត់ភ្លាម៖

-ណ្ហើយ! ណ្ហើយ! និយាយរួមបើឯងមិនឲ្យខ្ញុំរួមចំណែកធ្វើទេ ខ្ញុំមិនពិសាដាច់ខាត!

នេត្រសើចស្មើៗ ទាញដៃភ្ញៀវដែលនាងយល់ថាគួរឲ្យចូលចិត្តរូបនេះចូលសំដៅទៅកាន់ចង្ក្រាន ដើរទៅបណ្តើរមាត់ពោលប្រាប់បណ្តើរ៖

-ណ្ហើយចុះ! ឆ្លៀតពេលនេះ ខ្ញុំបង្រៀនឯងចៀនសាច់ទៅចុះ!

ចូលដល់ចង្ក្រាននេត្រដើរទៅបើកទូទឹកកកយកសាច់គោស្រស់ចេញមក មានទាំងបន្លែផង ភីណាឆ្លៀតពេលនោះពោលសួរភ្លាម៖

-ចៀនសាច់គោមែនទេ? ល្អ! ខ្ញុំចូលចិត្ត!

-និយាយមែនអ្ហេស៎? អញ្ជើញឯងយកចិត្តទុកដាក់មើលឲ្យមែនទែនណ៎ា! ឯងរៀនតាមខ្ញុំចុះធានាថាពេលហូបហើយ ទៅដល់ណាក៏នឹកឃើញវារហូតហ្នឹង!

ភីណាលើកចានមករៀបបន្លែបណ្តើរ មាត់វាចាតបបណ្តើរដែរ៖

-អួត៩! បាន! ចាំខ្ញុំភ្លក់ហើយសិនបានដឹង!...អ៊ូ!នេត្រអ្ហា មួយស្របក់ហើយម៉េចក៏មិនឃើញចាស់ទុំសោះ?

នេត្រដើរទៅហាន់សាច់ មាត់ឆ្លើយតបផង ដៃរាវរកកាំបិតផង៖

-ខ្ញុំមានតែប៉ាទេ ម៉ាក់ខ្ញុំគាត់អនិច្ចកម្មជិត១០ឆ្នាំហើយ! ប៉ាខ្ញុំគាត់ចេញទៅធ្វើការមុននេះបន្តិច ប៉ុណ្ណោះ ប៉ុន្តែកុំព្រួយអី យើងនៅក្បែរគ្នាស្រាប់ ឯងមានឱកាសច្រើនទៀតនឹងបានជួបគាត់ ប៉ាខ្ញុំស្លូតណាស់! ឯងឃើញគាត់មុខតែចូលចិត្តមិនខានទេ!

ភីណាទម្លាក់ទឹកមុខ នាងឈ្ងោកហាន់ប៉េងប៉ោះបណ្ដើររអ៊ូបណ្ដើរដូចជាកំពុងនិយាយឲ្យខ្លួនឯងស្ដាប់៖

-ឯងយ៉ាងណាក៏នៅគ្រាន់បើជាងខ្ញុំ ប៉ាម៉ាក់ខ្ញុំ លោកអនិច្ចកម្មទៅតាំងពីខ្ញុំនៅរៀនបឋមសិក្សាម្ល៉េះ ខ្ញុំរស់នៅតែជាមួយបងប្រុសរហូតមកទេ!

នេត្រដាក់ខ្ទះទៅលើចង្ក្រាន កាយវិការដូចជាស្ទាត់ជំនាញណាស់ ប៉ុន្តែមាត់នៅតែតបជាមួយភីណា៖

-ឲ្យតែបងប្រុសឯងគាត់ស្រលាញ់ឯងទៅ វាល្អហើយ! គិតថយក្រោយធ្វើអី?

បន្ទះសាច់គោត្រូវបានទម្លាក់បណ្ដែតទៅលើខ្ទះ ជះក្លិនឈ្ងុយឈ្ងប់ពេញផ្ទៃបន្ទប់បាយមួយរំពេច ភីណាញញឹមស្រស់ដោយលាន់មាត់៖

-ឈ្ងុយណាស់! អូ៎ ម៉េចក៏ឯងស្ទាត់ម៉េះ? រៀនធ្វើម្ហូបពីណាមក?

នេត្រញញឹមបណ្ដើរតបបណ្ដើរ៖

-ទៅរៀននៅស្រុកគេ មិនមែនស្ពាយយកអ្នកបម្រើទៅតាមដែរទេ! បើអត់ចេះធ្វើខ្លួនឯង មានតែអត់ហូប?!

ភីណាដៀងភ្នែកសម្លឹងទៅនារីនិស្សិតមកពីបរទេសដែលកំពុងចម្អិនអាហារយ៉ាងស្ទាត់ជំនាញ នារីដែលមានរូបរាងទន់ភ្លន់យ៉ាងនេះ បែរជាហ៊ានសសៀរចូលទៅកាន់ "ផ្ទះដែលអ្នកផងខ្លាចរអាគ្រប់គ្នា" នាកណ្ដាលយប់ស្ងាត់ ចំជាគួរឲ្យស្ងើចក្នុងចិត្តណាស់។

បន្តិចក្រោយមក សំណាងប្អូនប្រុសរបស់នេត្រ និងវិទូចុះមកពីជួសជុលបំពង់ទឹកជុំគ្នាដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលជាទីបំផុត។

ពេលបរិភោគបានកន្លងផុតទៅ វិទូលាទៅវិញ ទុកឲ្យនារីទាំងពីរនៅជជែកគ្នាយ៉ាងរីករាយ ហើយស្និទ្ធស្នាលប្រៀបបីដូចជាមិត្តភ័ក្តិចាស់តាំងពីយូរណាស់មកហើយអញ្ចឹងដែរ។

នេត្រនាំភីណាឡើងទៅកាន់បន្ទប់ផ្ទាល់របស់ខ្លួន ឡើងមកដល់ភ្លាមភីណាប្លែកភ្នែកជាមួយនឹងផ្ទៃបន្ទប់ដែលរចនារៀបចំតាមបែបអឺរ៉ុបទាំងសង្ហារិមទាំងអ្វីៗគ្រប់យ៉ាង ប៉ុន្តែទោះបីថាទីនេះខុសប្លែកពីគេហដ្ឋានរបស់ខ្លួនក៏ដោយ ក៏ភីណាយល់ថាក៏ជាបរិយាកាសប្លែកគួរជាទីមនោរម្យម្យ៉ាងដែរ។

នាងបានប្រទះភ្នែកនឹងសៀវភៅប្រលោមលោកបរទេសជាច្រើន មានភាគច្រើននិយាយពីរឿងខ្មោចព្រាយបិសាច។ មកទល់ពេលនេះទើបតរុណីយល់ថា ហេតុដែលនារីនិស្សិតហ៊ានផ្លោះរបងឆ្លងទៅកាន់ផ្ទះខ្លួនទាំងយប់ស្ងាត់ក៏ព្រោះតែនាងមាននិស្ស័យចូលចិត្តស្វែងយល់ពីរឿងវិញ្ញាណខ្មោចបិសាចនានា ម្ល៉ោះហើយឆ្លៀតពេលនោះដែរ ភីណាលាន់មាត់សួរទៅកាន់ម្ចាស់បន្ទប់ភ្លាមៈ

នែ៎! ឯងថាឯងនឹងនិយាយរឿងខ្មោចប្រាប់ខ្ញុំ ពេលខ្ញុំមករកឯងដល់ផ្ទះនោះអី? ឥឡូវនេះចាប់ផ្ដើមទៅ!

នេត្រងាកមកសម្លឹងមុខភីណា នាងពោលសួរវិញភ្លាមដែរៈ

-ឯងពិតជាអត់ដឹងអីសោះមែនអ្អេស់ភីណា?

**ភាគទី១០**

ភីណាងក់ក្បាលផ្ងក់ៗដោយបើកភ្នែកគ្រលួងបង្ហាញភាពស្មោះត្រង់។ នេត្រឃើញហើយក៏បន្លឺសួរបន្តៈ

-អញ្ចឹងឯងអត់ឆ្ងល់ទេថាម៉េចបានម្ចាស់ផ្ទះមុន គេទុកផ្ទះនេះចោលយូរឆ្នាំមកហើយ?

ភីណារឹតតែងីងើជាងមុន នាងតបវិញដោយមិនដឹងរឿងអ្វីទាំងអស់ៈ

-ខ្ញុំមិនដឹងរឿងអីទេ! ផ្ទះនេះគឺបងប្រុសទាក់ទងតាមក្រុមហ៊ុនទិញលក់ទេតើ! ឃើញវាធំហើយបរិយាកាសគ្រាន់បើណាស់ ក៏ពេញចិត្តទាំងអស់គ្នាទៅ ឯក្រុមហ៊ុនទិញលក់ក៏គេមិនបានរំលឹកថាផ្ទះនេះម្ចាស់មុនគេទើបតែរើចេញ ឬក៏ទុកចោលយូរឆ្នាំហើយ ឬយ៉ាងណានោះដែរនេត្រ! ក្រោយមកនេះខ្ញុំឮគេខ្លះនិយាយបន្លាចពីរឿងដែលថាផ្ទះថ្មីខ្ញុំនេះមានខ្មោច ដំបូងខ្ញុំអត់ចង់ខ្វល់ទេ តែដល់ឮគេនិយាយច្រើនគ្នាពេក ចង់ភ្ញាក់ផ្អើលដែរ! ប៉ុន្តែខ្ញុំរើមកនៅជាងមួយខែហើយ! មិនដែលឃើញអីគួរឲ្យចាប់អារម្មណ៍មែន!

នេត្រដើរមកអង្គុយក្បែរភីណា នាងនៅស្ងៀមសម្លឹងមុខភីណាបន្តិច ទើបហើបមាត់ពោលមួយៗ៖

-ភីណា! ឯងជឿខ្ញុំហើយត្រៀមខ្លួនទប់ទល់ជាមួយការពិតចុះ ខ្ញុំមិនកុហកឯងទេ ខ្ញុំត្រូវតែប្រាប់ឯងដោយត្រង់គ្មានលាក់លៀមថាផ្ទះឯងមានខ្មោចពិតមែន!

ភីណានៅស្ងៀមមិនមានចេញស្ដីថាយ៉ាងម៉េចទេ ប៉ុន្តែនាងកំពុងរិះគិតដោយសង្ស័យក្នុងចិត្តរួចស្រេចទៅហើយ កន្លងមកនេះក្នុងផ្ទះក៏មានរឿងមិនប្រក្រតីច្រើនណាស់ដែរ លុះដល់មកឮនេត្រនិយាយរឿងបែបនេះទៀត ភីណាកាន់តែច្របូកច្របល់ដោយក្ដីខ្វល់ខ្វាយ ប៉ុន្តែនាងនៅព្យាយាមពោលបដិសេធ៖

-ឯងថាឲ្យខ្ញុំជឿ ប៉ុន្តែជឿក៏ត្រូវមានហេតុផលច្បាស់លាស់បន្តិចដែរ ផ្ទះមនុស្សនៅយ៉ាងអញ្ចឹងម៉េចក៏បែរជាមានខ្មោចទៅកើត?

នេត្រហើបមាត់តបវិញភ្លាម៖

-ផ្ទះរបស់ឯងធ្លាប់មានមនុស្សស្លាប់!

ពាក្យសម្ដីមួយឃ្លាចុងក្រោយនេះហាក់ដូចជាមានប្រសិទ្ធភាពសម្បើមណាស់ បណ្ដាលឲ្យនាងក្រមុំភីណាងាកមកសម្លឹងគូសន្ទនាថ្មៃមិនដាក់ភ្នែក នាងនៅធ្មឹងស្ងៀមអស់មួយខណៈទើបពោលឡើងមួយៗ៖

-មែន? ឯងដឹងរឿងអីខ្លះពីផ្ទះខ្ញុំឆាប់និយាយទៅ!?

ក្រមុំនិស្សិតឈ្ងោកមុខតបមួយៗវិញ ដោយប្រាកដប្រជាថា៖

-រឿងនេះខ្ញុំឮតាំងតែពីបួនឆ្នាំមុនមកម្ល៉េះ! គឺមីងសានជាអ្នកនិយាយប្រាប់!

ភីណាលាន់មាត់សួរវិញយ៉ាងរហ័ស៖

-ឯងឮយ៉ាងម៉េចខ្លះ? រួចចុះ...មីង...មីងសានជាអ្នកណា?

នេត្រសម្លឹងមុខភីណាបន្តិចទើបដាក់ភ្នែកចុះ មាត់ឆ្លើយតបវិញ៖

-មីងសានជាអ្នកបម្រើជំនិតរបស់គ្រួសារខ្ញុំ តាំងតែពីតូចមកម្ល៉េះ! ឥឡូវនេះ មីងសានស្លាប់បាត់ទៅហើយ!

ទោះយ៉ាងណាក៏ឆ្លងកាត់សភាពបែបនេះ ភីណារឹតតែយល់ថានេត្រមិនមែននិយាយកុហកខ្លួនតាមតែចិត្តនឹកឃើញនោះទេ នាងនៅស្ងៀមសញ្ជឹងគិតបន្តិចទើបពោលសួរបន្ត៖

-មីងសានកាលពីនៅរស់ និយាយប្រាប់ឯងថាម៉េចខ្លះ?

នេត្រសម្លឹងមុខភីណាបន្តិច ទើបហើបមាត់វាចាតប៖

-នោះគឺជារឿងពិត បើមិននិយាយប្រាប់ឯងក៏មិនកើតដែរ! ផ្ទះឯងនោះកាលពីបួនឆ្នាំមុនម្ចាស់ផ្ទះជាសេដ្ឋីល្បីម្នាក់គឺលោកឪណូ ប្រពន្ធគាត់ក៏ស្អាតមិនចាញ់បងថ្លៃឯងទេ! នាងធ្លាប់ជាអតីតអ្នកចម្រៀង ឯងស្គាល់អត់គឺឈ្មោះអមរា តែពេលបានក្លាយជាសេដ្ឋិនី ល្បីថាគាត់ក្លាយជាមនុស្សចិត្តអាក្រក់ កំណាញ់ដាក់បាវព្រាវ អ្នកជិតខាងភូមិផងរបងជាមួយ អ្នកណាក៏រិះគន់ដែរ!

ភីណាដូចជាជក់ចិត្តជាមួយរឿងចម្លែកដែលខ្លួនមិនធ្លាប់ឮនេះណាស់ នាងបន្លឺសួរបន្ថែមភ្លាម៖

-បន្ទាប់មកយ៉ាងម៉េចទៀត?

នេត្រពោលបន្តដោយទឹកមុខស្ងៀមស្ងាត់ ហាក់ដូចជាកំពុងលង់យ៉ាងជ្រៅទៅក្នុងដំណើររឿង៖

-ពីរនាក់ប្តីប្រពន្ធនេះគ្មានកូនមួយនឹងគេទេ តាមដែលឮមីងសានប្រាប់គឺថាកាលណោះប្តីប្រពន្ធនេះមិនសូវល្អនឹងគ្នាដូចគ្រួសារគេដទៃផង ព្រោះប្រពន្ធឧស្សាហ៍រករឿងប្រចណ្ឌប្តីគាត់ខុសទំនងសូម្បីតែអ្នកបម្រើក្មេងៗក្នុងផ្ទះ ក៏ឧស្សាហ៍ត្រូវគាត់ធ្វើបាបព្រោះតែការប្រចណ្ឌដែរ។ ឯលោកសេដ្ឋីប្តីគាត់នោះវិញក៏ជាមនុស្សខិលខូចទៀត ព្រោះតែអញ្ចឹងហើយទើបមានរឿងធំផ្ទុះឡើង។

ភីណានៅស្ងៀមសម្ងំស្តាប់ នាងមិនដឹងថារឿងធំដែលនារីនិស្សិតចង់រំលឹកនៅពេលនេះគឺជារឿងអ្វីទេ ប៉ុន្តែនាងយល់ថាមុខតែមានទាក់ទងដល់រឿង "មនុស្សស្លាប់" រឿង"ខ្មោចលង"

ដែលនេត្របានរំលឹកឡើងកាលពីដំបូងនោះមិនខានទេ។ ទោះយល់ឃើញយ៉ាងនេះក្តី ក៏តរុណីនៅសម្ងំស្ងៀមចាំស្តាប់នេត្ររៀបរាប់ដែរ ភ្លាមនោះនេត្ររៀបរាប់បន្តៈ

-តាមដែលគ្នានៅចាំពាក្យដែលមីងសានរៀបរាប់ប្រាប់គឺកាលណោះក្នុងផ្ទះនោះមានអ្នកបម្រើក្រមុំម្នាក់ឈ្មោះនាង កែវ នាងមានរូបរាងស្រស់ស្អាតតាមបែបក្រមុំស្រុកស្រែ ព្រោះតែយ៉ាងនេះហើយទើបនាងឧស្សាហ៍ត្រូវលោកស្រីសេដ្ឋីនីម្ចាស់ផ្ទះស្អប់នាងកែវជាងអ្នកបម្រើផ្សេងៗទៀត។ គាត់ប្រើឲ្យធ្វើការងារជាទម្ងន់គ្មានទំនេរ ជេរស្តីបន្ទោសព្រឹកល្ងាច ជួនមានទាំងបង្អត់បាយទឹក។ ដោយសារនាងកែវជាក្មេងកំព្រាគ្មានទីពឹងពាក់ ម្ល៉ោះហើយដោយមីងសានកាលណោះនៅផ្ទះជាប់អញ្ចឹងគាត់មាននិយាយស្តីទៅមកច្រើនដងជាមួយនាងកែវ អញ្ចឹងហើយរឿងទាំងប៉ុន្មានសុទ្ធតែនាងកែវនិយាយប្រាប់មីងសានទាំងអស់។ ក្រោយមកសេដ្ឋីនោះមានគំនិតអាក្រក់ចង់ធ្វើបាបរូបកាយនាងកែវ គឺយប់នោះដែរហើយដែលមីងសានប្រាប់ថាគាត់បានឃើញផ្ទាល់ភ្នែកថានាងកែវស្លាប់។

ម្តងណោះភីណាលែងសម្ងំស្ងៀមទៀតហើយ នាងក្រមុំងើបមុខសួរទៅកាន់គូសន្ទនាភ្លាមៈ

-នាងកែវស្លាប់អ្ហស់? ហេតុអ្វី? អ្នកណាសម្លាប់នាង? ហើយ ហើយម៉េចក៏! មីងសានរបស់ឯងគាត់ដឹងរឿងនោះ?

នេត្រប្រកាន់អាកប្បកិរិយាដដែលតបបន្តទៅវិញៈ

-បន្ទប់ចង្ក្រានរបស់ឯងខាងក្រោមនោះ គឺវាទល់មុខនឹងបន្ទប់បណ្ណាល័យផ្ទះខ្ញុំ ប៉ុន្តែដោយបណ្ណាល័យខ្ញុំនៅជាន់លើខ្ពស់ជាងបន្ទប់ឯង ម្ល៉ោះហើយកាលមីងសានចូលរៀបចំក្នុងបណ្ណាល័យ ចៃដន្យគាត់បានប្រទះឃើញយ៉ាងច្បាស់នូវហេតុការណ៍ទាំងប៉ុន្មានក្នុងផ្ទះបាយឯងគ្មានចន្លោះទេ!

នាងក្រមុំភីណាព្យាយាមសាកល្បងត្រិះរិះសម្តីក្រមុំម្ចាស់ផ្ទះរូបនេះ ប៉ុន្តែភ្លាមនោះនេត្រស្រាប់តែស្ទុះក្រោកអូសដៃភីណាចេញពីបន្ទប់ទាំងមាត់ពោលញាប់ស្មេរះ

-ខ្ញុំនាំឯងទៅមើលផ្ទាល់ភ្នែកចុះ!